# សទ្ទវិសេស

# បែបទន្ទេញបទមាលា




ព្រះមហាភិរម្យ សុវណ្ណបញ្ញោ មហា ៨ ប្រយោគ

ព.ស. ២៥៦៧ គ.ស. 2023

# បែបទន្ទេញបទមាលា

* * * * * * * * *

## សម្រាប់

-ឧទ្ទេសាចារ្យនិងសាស្ត្រាចារ្យភាសាបាឡីគ្រប់កម្រិត

-សមណៈសិស្សទន្ទេញចាំមាត់

-ឧបាសកឧបាសិកាដែលចង់សិក្សាភាសាបាឡី

-អ្នកសិក្សាស្រាវជ្រាវភាសាបាឡី

-មហាជនទូទៅដែលចាប់អារម្មណ៍ក្នុងភាសាបាឡី

* * * * * * * * *

-អ្នករៀបរៀង  ព្រះមហាភិរម្យ  សុវណ្ណបញ្ញោ (មហា ៨ ប្រយោគ)
-តួនាទី ព្រះឧទ្ទេសាចារ្យ ថ្នាក់ទី ២ សាលាពុទ្ធិកបឋមសិក្សាម៉ាចសត្ថារាម
-អាសយដ្ឋាន វត្តរតនារាម (ផ្សារកណ្តាល) ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
-បោះពុម្ព លើកទី ១ ព.ស. ២៥៦៧ គ.ស. ២០២៣

# វចីមុខ

**នវង្គសត្ថុសាសន៍** គឺ ពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តាដ៏ប្រកបដោយអង្គ ៩ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតៈ និង វេទល្លៈ ដែលពាក្យប្រៀនប្រដៅទាំងនេះត្រូវបានព្រះបរមសាស្តាបង្រៀនវេនេយ្យជនដោយមាគធភាសា ឬ ភាសាបាឡី ។

ពុទ្ធសាសនិកជនដែលចាប់អារម្មណ៍សិក្សាព្រះធម៌របស់ព្រះបរមសាស្តាដ៏ប្រកបដោយអង្គ ៩ នោះគប្បីសិក្សា គោលភាសា គឺ វ្យាករណ៍ ជាមុនសិន ដើម្បីបានជាកូនសោរសម្រាប់ចូលទៅសិក្សាស្វែងយល់ព្រះត្រៃបិដក អដ្ឋកថា ដីកា ជាដើម ព្រោះកាលបើមិនបានសិក្សាវ្យាករណ៍ជាមុនហើយ តែទៅសង្វាតសិក្សាព្រះត្រៃបិដកតែម្តង ព្រះបោរាណាចារ្យ ដែលមានបទពិសោធន៍ខាងភាសាបាឡីប្រាប់ ថា បុគ្គលនោះប្រាកដជាសង្ស័យរាល់បទដែលមានក្នុងព្រះត្រៃបិដកនោះ ប្រៀបបីដូចដំរីខ្វាក់ត្រាច់ចរទៅក្នុងព្រៃដូច្នោះ ។

"**បែបទន្ទេញបទមាលា**" នេះ ខ្ញុំ(ព្រះមហាភិរម្យ)បានរៀបរៀងឡើង កំលុងបង្រៀនវៃយាករណ៍បាឡីដល់សមណៈសិស្សក្នុងវត្តរតនារាម ហៅ **វត្តផ្សារកណ្តាល** ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយបង្គាប់ឲ្យសិស្សគ្រប់អង្គទន្ទេញចាំមាត់រាល់បទមាលា និង ឲ្យធ្វើលំហាត់រូបសម្រេចបទមាលាទាំងនោះជាប្រចាំ នៅពេលឃើញថា សិស្សរាល់អង្គចាប់ផ្តើមចេះចាំបទមាលាបណ្តើរ ៗ ហើយ ខ្ញុំក៏ប្រមែប្រមូលនិងរៀបរៀងបទមាលាទាំងនោះជាសៀវភៅឡើង ដើម្បីទុកជាបែបសម្រាប់ទន្ទេញនិងរំលឹកបទមាលាទាំងនោះ ក្រៅពីសៀវភៅ **បែបទន្ទេញបទមាលា** នេះ ខ្ញុំនៅរៀបរៀងសៀវភៅ **បែបធ្វើរូបបទមាលា** មួយទៀត សម្រាប់ឲ្យសិស្សធ្វើលំហាត់រូបសម្រេចបទមាលាទាំងនោះ ។

**បទមាលា** បានដល់ កម្រងបទរបស់នាមសព្ទដែលចុះវិភត្តិទាំង ១៤ គឺ **សិ យោ,អំ យោ, នា ហិ, ស នំ, ស្មា ហិ, ស នំ, ស្មឹ សុ** ដូចជា **បុរិស** ជា **នាមសព្ទ** នៅពេលចុះ **សិ** វិភត្តិ បានរូបជា **បុរិសោ** ហៅថា **បទ**, នៅពេល **បុរិស** ចុះ **យោ**, ចុះ **អំ** ជាដើមទៅ រហូតដល់ ចុះ **សុ** បានរូបជា **បុរិសេសុ** ជាទីបំផុត, ហៅ **បុរិសោ** ជាដើម រហូត ដល់ **បុរិសេសុ** ថាជា **បទមាលា** ។

សង្ឃឹម ថា "**បែបទន្ទេញបទមាលា**" នេះ គង់មានឧបការៈតិចឬច្រើនដល់សមណៈសិស្សដែលកំពុងសិក្សាវៃយាករណ៍ភាសាបាឡី បើអ្នកសិក្សាឃើញខុសឆ្គងដោយប្រការណា អ្នករៀបរៀងនឹងកែតម្រូវនៅពេលក្រោយ ៕

# និទានកថា

ព្រះធម៌វិន័យដែលព្រះបរមសាស្តារបស់យើងទាំងឡាយទ្រង់បានសម្តែងទុក និង បញ្ញត្តទុកដើម្បីប្រយោជន៍សុខដល់មនុស្សជាតិទាំងពួង ឈ្មោះថា **បរិយត្តិធម៌** ។ បណ្តាព្រះសទ្ធម្ម គឺ បរិយត្តិធម៌ បដិបត្តិធម៌ និង បដិវេធធម៌ នោះ, **បរិយត្តិធម៌** ចាត់ជាឫសកែវ និង ជាមូលដ្ឋាននៃការតាំងនៅរបស់ព្រះពុទ្ធសាសនា ព្រោះថា ដរាបណា បរិយត្តិធម៌នៅមាន បដិបត្តិធម៌ និង បដិវេធធម៌ រមែងកើតឡើងបានដរាបនោះ បើបរិយត្តិធម៌សាបសូន្យហើយ បដិបត្តិធម៌ និង បដិវេធធម៌ ក៏មិនអាចកើតឡើងបានឡើយ ដរាបណា មាត់ស្រះនៅមាន ទឹកនិងផ្កាឈូករមែងស្ថិតនៅបានដរាបនោះ បើមាត់ស្រះបាក់ធ្លាយហើយ ទឹកនិងផ្កាឈូកគ្មានទីអាស្រ័យក៏មិនអាចស្ថិតនៅបាន សមដូចព្រះអដ្ឋកថាចារ្យមហាប្រាជ្ញក្នុងវង្សនៃព្រះសទ្ធម្មបានមានថេរដីកាទុក ថា

**យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិប្បតិ**
**តាវ ទក្ខន្តិ អាលោកំ សូរិយេ អព្ភុដ្ឋិតេ យថា ។**

ដរាបណា ព្រះសូត្រ និង ព្រះអភិធម្ម នៅស្ថិតស្ថេរ, ដរាបណា ព្រះវិន័យនៅរុងរឿង (បដិបត្តិធម៌ និង បដិវេធធម៌ ) នឹងគង់វង្សស្ថិតស្ថេរនៅ ដរាបនោះ បីដូចព្រះអាទិត្យនៅមានពន្លឺរះឡើងដូច្នោះ ។

**សុត្តន្តេសុ អសន្តេសុ បមុដ្ឋេ វិនយម្ហិ ច**
**តមោ ភវិស្សតិ លោកេ សូរិយេ អត្ថង្គតេ យថា ។**

នៅពេលព្រះសូត្រ និង ព្រះអភិធម្ម មិនមាន និង ព្រះវិន័យសាបសូន្យ សេចក្តីងងឹតនឹងកើតមានក្នុងលោក បីដូចព្រះអាទិត្យអស្តង្គតទៅដូច្នោះ ។

**សុត្តន្តេសុ រក្ខិតេ សន្តេ បដិបត្តិ ហោតិ រក្ខិតា**
**បដិបត្តិយំ ឋិតោ ធីរោ យោគក្ខេមា ន ធំសតិ ។**

នៅពេលព្រះសូត្រ និង ព្រះអភិធម្ម នៅមានការរក្សាការពារ ការបដិបត្តិក៏ឈ្មោះថា នៅមានការរក្សាការពារដែរ ជនជាបណ្ឌិតដែលស្ថិតនៅក្នុងការបដិបត្តិហើយ រមែងមិនឃ្លាតចាកព្រះនិព្វានឡើយ ។

ព្រោះហេតុនោះ ពុទ្ធបរិស័ទត្រូវជួយគ្នាថែរក្សាបរិយត្តិធម៌ដោយការលើកតម្កើងនិងសិក្សារៀនសូត្រឲ្យចេះដឹងហើយនាំយកទៅបង្ហាត់បង្រៀនដល់អនុជនជំនាន់ក្រោយតទៅ ឬ ជួយគ្នាទំនុកបម្រុងភិក្ខុសាមណេរដែលសិក្សាបរិយត្តិធម៌ឲ្យក្លាយជាធនធានមនុស្សផ្នែកសាសនធម៌ ដូចយ៉ាងពុទ្ធសាសនិកជនក្នុងសម័យកាលមុន ៗ ធ្លាប់ធ្វើទុកមកហើយដូច្នោះ ។

ការសិក្សារៀនសូត្របរិយត្តិធម៌គប្បីសិក្សារៀនសូត្រយ៉ាងមានរបៀបបែបផែន មានគ្រូអាចារ្យដែលមានចំណេះវិជ្ជាការត្រឹមត្រូវជួយណែនាំបង្ហាត់បង្រៀន ប្រសិនបើសិក្សារៀនសូត្រដោយខ្លួនឯងដោយគ្មានរបៀបបែបផែន និង គ្មានគ្រូអាចារ្យបង្ហាត់បង្រៀនត្រឹមត្រូវទេ អាចធ្វើឲ្យយល់ខុសឃ្លៀងឃ្លាតចាកព្រះសទ្ធម្មបាន ហើយបកស្រាយខ្លឹមសារព្រះសទ្ធម្មនោះបែបអត្តនោមតិយ៉ាងខុសឆ្គង ។

ព្រះធម៌វិន័យដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បានសម្តែងនិងបញ្ញត្តទុកនោះ មានងាយខ្លះពិបាកខ្លះ រាក់ខ្លះ ជ្រៅខ្លះ ជួនកាល យើងអាចយល់បានដោយខ្លួនឯង ជួនកាលយើងមិនអាចយល់បានដោយខ្លួនឯង ព្រោះហួសកម្លាំងសតិប្រាជ្ញារបស់យើង ត្រូវអាស្រ័យអ្នកចេះដឹងជួយបកស្រាយមួយជាន់ទៀតទើបអាចយល់បាន ។

ការសិក្សារៀនសូត្របរិយត្តិធម៌ ដែលចាត់ទុកថាមានរបៀបបែបផែនដ៏ត្រឹមត្រូវនោះ គឺ ការសិក្សារៀនសូត្រទៅតាមគោលការណ៍ដែលព្រះគន្ថរចនាចារ្យបានរៀបចំទុកមកហើយ គឺ ព្រះត្រៃបិដក អដ្ឋកថា ដីកា និង គម្ពីរសទ្ទវិសេសនានា ។

គោលភាសាចាត់ជារឿងសំខាន់និងចាំបាច់ដែលត្រូវសិក្សារៀនសូត្រមុនគេ ។ គម្ពីរសទ្ទវិសេសជាគម្ពីរមូលដ្ឋានសម្រាប់គោលភាសាបាឡី ដែលត្រូវបានព្រះបោរាណាចារ្យចងក្រងទុកដើម្បីសិក្សារៀនសូត្របរិយត្តិធម៌ ។

គម្ពីរវេយ្យាករណ៍បាឡី មាន ៤ បែប ( system ) គឺ

១. បែប កច្ចាយនៈវេយ្យាករណ៍ តែងដោយព្រះមហាកច្ចាយនថេរៈ

២. បែប មោគ្គល្លានៈវេយ្យាករណ៍ តែងដោយព្រះមោគ្គល្លានថេរៈ

៣. បែប សទ្ទនីតិ វេយ្យាករណ៍ តែងដោយព្រះអគ្គវង្សាចារ្យ

៤. បែប សទ្ទសង្គហៈវេយ្យាករណ៍

បែបកច្ចាយនៈវេយ្យាករណ៍ និង មោគ្គល្លាន មានគម្ពីរអធិប្បាយសេចក្តីរាប់រយគម្ពីរទៀត ក្នុងនោះ គម្ពីរបទរូបសិទ្ធិអធិប្បាយរំគាយសេចក្តីរបស់កច្ចាយនៈវេយ្យាករណ៍មិនសង្ខេបពេកមិនពិស្តារពេក ល្មមយកមកធ្វើជាបែបសម្រាប់រៀបរៀងបាន ព្រោះមានសូត្រនិងវុត្តិងាយយល់ ។

ហេតុនោះ សៀវភៅ “ **បែបទន្ទេញបទមាលា** ” នេះ ត្រូវបានរៀបរៀងឡើងស្របតាមគម្ពីរបទរូបសិទ្ធិនោះ ដើម្បីឲ្យសមណៈសិស្សយកទៅទន្ទេញចាំមាត់និងធ្វើរូបសម្រេចបទមាលានៅពេលចូលរៀនក្នុងថ្នាក់ ។

# អក្សរកាត់

| | |
|---|---|
| ប. | បឋមា |
| អា. | អាលបនៈ |
| ទុ. | ទុតិយា |
| ត. | តតិយា |
| ច. | ចតុត្ថី |
| មី. | បញ្ចមី |
| ឆ. | ឆដ្ឋី |
| ស. | សត្តមី |
| ឯក. | ឯកវចនៈ |
| ពហុ. | ពហុវចនៈ |
| បុំ. | បុល្លិង្គ |
| ឥ. | ឥត្ថិលិង្គ |
| នបុំ. | នបុំសកលិង្គ |
| វិ. | វិគ្គហៈ |

## មាតិកា ទំព័រ


វចីមុខ ..........................................................................................................[ 02 ]

និទានកថា.......................................................................................................[ 03 ]

អក្សរកាត់........................................................................................................[ 05 ]

ពាក្យប្រែរបស់វិភត្តិ...............................................................................................[ 12 ]

១. **បុល្លិង្គ** ........................................................................................................[ 13 ]

-បុរិស [ ប្រុស ], មន [ ចិត្ត ] អការន្ត .....................................................................[ 13 ]

-អាប [ទឹក], ថាម [កម្លាំង] អការន្ត .........................................................................[ 17 ]

-គុណវន្តុ [អ្នកដ៏មានគុណ] ឧការន្ត .......................................................................[ 18 ]

-ហិមវន្តុ [ដែលមានទឹកកក], សតិមន្តុ [ដែលមានសតិ] ឧការន្ត ..................................[ 19 ]

-មឃវន្តុ [ស្តេចសក្កៈដែលមានឈ្មោះថា មឃៈ] ឧការន្ត បុំ. ........................................[ 20 ]

-គច្ឆន្ត [កាលទៅ កំពុងទៅ] អការន្ត ......................................................................[ 21 ]

-ភវន្ត [អ្នកដ៏ចម្រើន], ភទន្ត [លោកដ៏ចម្រើន] អការន្ត ...............................................[ 22 ]

-សន្ត [កាលមាន,កំពុងមាន, សប្បុរស], រាជ [ព្រះរាជា,ស្តេច] អការន្ត ..........................[ 23 ]

-ព្រហ្ម [ព្រហ្ម], អត្ត [ខ្លួន] អការន្ត .........................................................................[ 24 ]

-សខ [សម្លាញ់], អាតុម [ខ្លួន] អការន្ត .....................................................................[ 25 ]

-បុម [ប្រុស], យុវ [កម្លោះ] អការន្ត ........................................................................[ 26 ]

-សា [ ឆ្កែ ], អគ្គិ [ ភ្លើង ] ឥការន្ត ............................................................................[ 27 ]

-ទណ្ឌី [ អ្នកមានឈើច្រត់ ] ឦការន្ត, ភិក្ខុ [ ភិក្ខុ ] ឧការន្ត ...........................................[ 29 ]

-ហេតុ [ ហេតុ ], ជន្តុ [ សត្វ ] ឧការន្ត .....................................................................[ 31 ]

-សត្ថុ [ ព្រះសាស្តា ], កត្តុ [ អ្នកធ្វើ ] ឧការន្ត.................................................................[ 32 ]

-សកមន្ធាតុ [ស្តេចសកមន្ធាតុ] បិតុ [បិតា] ឧការន្ត.....................................................[ 34 ]

-អភិភូ [ព្រះជាម្ចាស់], សហភូ [ អ្នកកើតព្រមគ្នា] ឩការន្ត ........................................[ 35 ]

-សព្វញ្ញូ [ ព្រះសព្វញ្ញូ ] ឩការន្ត, គោ [ គោ ] ឱការន្ត ........................................[ 36 ]

**២. ឥត្ថិលិង្គ** ........................................[ 38 ]

-កញ្ញា [ ស្រីតូច ], អម្មា [ ម៉ាក់ ] អាការន្ត ........................................[ 38 ]

-រត្តិ [ រាត្រី ], បត្តិ [ចំណែកបុណ្យ] ឥការន្ត ........................................[ 41 ]

-ឥត្ថី [ស្រ្តី], នទី  [ស្ទឹង] ឦការន្ត ........................................[ 43 ]

-បុថវី [ផែនដី], គាវី [គោញី] ឦការន្ត ........................................[ 45 ]

-គុណវតី  [ដែលមានគុណ], គុណវន្តី  [ដែលមានគុណ]  ឦការន្ត ........................................[ 46 ]

-គច្ឆន្តី [ កំពុងទៅ ], ករោន្តី [ កំពុងធ្វើ ] ឦការន្ត ........................................[ 48 ]

-បោក្ខរណី [ ស្រះឈូក ], យាគុ [ បបរ ] ឧការន្ត ........................................[ 49 ]

-មាតុ [ មាតា ] ឧការន្ត, ជម្ពូ [ ដើមព្រីង ] ឩការន្ត ........................................[ 51 ]

-គោ [ គោញី ] ឱការន្ត ........................................[ 52 ]

**៣. នបុំសកលិង្គ** ........................................[ 54 ]

-ចិត្ត [ ចិត្ត ], កម្ម [ កម្ម, អំពើ ទង្វើ,ការងារ ] អការន្ត ........................................[ 54 ]

-ថាម [ កម្លាំង,ថាមពល ], អទ្ធ  [ ផ្លូវឆ្ងាយ,កាលយូរអង្វែង ] អការន្ត  ........................................[ 57 ]

-គុណវន្តុ [ ដែលមានគុណ ] ឧការន្ត, គច្ឆន្ត [ កំពុងទៅ ] អការន្ត ........................................[ 58 ]

-អស្សទ្ធា [ គ្មានសទ្ធា ], មុខនាសិកា [ មាត់និងច្រមុះ ] អាការន្ត ........................................[ 59 ]

-អដ្ឋិ [ ឆ្អឹង,គ្រាប់ផ្លែឈើ ] ឥការន្ត, សុខការី [ ដែលធ្វើនូវសេចក្តីសុខ ] ឦការន្ត ........................................[ 60 ]

-អាយុ [ អាយុ ] ឧការន្ត, គោត្រភូ  [ គោត្រភូ ] ឩការន្ត ........................................[ 62 ]

-ចិត្តគោ [ ដែលមានគោពពាល ]  ឱការន្ត ........................................[ 64 ]

**៤. សព្ពនាម**


**៤. សព្ពនាម** ........................................ [ 66 ]

-សព្ព [ ទាំងពួង ] អការន្ត បុំ. ........................................ [ 67 ]

-សព្ពា [ ទាំងពួង ] អាការន្ត ឥ. ........................................ [ 68 ]

-សព្ព [ ទាំងពួង ] អការន្ត នបុំ. ........................................ [ 68 ]

-កតរកតម [ ពួកណាខ្លះ ] អការន្ត បុំ. ........................................ [ 69 ]

-កតរកតមា [ ពួកណាខ្លះ] អាការន្ត ឥ. ........................................ [ 69 ]

-កតរកតម [ ពួកណាខ្លះ ] អការន្ត នបុំ. ........................................ [ 70 ]

-អាទិ [ ខាងដើម,ជាដើម ] ឥការន្ត បុំ. ........................................ [ 71 ]

-អាទិ [ ខាងដើម,ជាដើម ] ឥការន្ត ឥ........................................ [ 71 ]

-អាទិ [ ខាងដើម,ជាដើម ] ឥការន្ត នបុំ. ........................................ [ 72 ]

-បុព្ព [ ខាងមុខ ] អការន្ត បុំ. ........................................ [ 72 ]

-បុព្ពា [ ទិសខាងកើត ] អាការន្ត ឥ. ........................................ [ 73 ]

-បុព្ព [ ខាងមុខ ] អការន្ត នបុំ. ........................................ [ 73 ]

-បុព្ពាបរ [ ខាងមុខនិងខាងក្រោយ ] អការន្ត បុំ. ........................................ [ 74 ]

-បុព្ពាបរា [ ទិសខាងកើតនិងទិសខាងលិច ] អាការន្ត ឥ. ........................................ [ 74 ]

-បុព្ពាបរ [ ខាងមុខនិងខាងក្រោយ ] អការន្ត នបុំ. ........................................ [ 75 ]

-ទក្ខិណបុព្ពា [ ទិសអាគ្នេយ៍ ] អាការន្ត ឥ. ........................................ [ 76 ]

-យ [ ន៉ា,ឯន៉ា ] អការន្ត បុំ. ........................................ [ 76 ]

-យា [ ន៉ា,ឯន៉ា ] អាការន្ត ឥ. ........................................ [ 77 ]

-យ [ ន៉ា,ឯន៉ា ] អការន្ត នបុំ. ........................................ [ 77 ]

-ត [ នោះ ] អការន្ត បុំ. ........................................ [ 79 ]

-តា [ នោះ ] អាការន្ត ឥ. ........................................ [ 79 ]

-ត [ នោះ ] អការន្ត នបុំ. ..........................................................................................[ 80 ]
-ឯត [ ហ្នឹង,និះ,នុះ ] អការន្ត បុំ. ....................................................................................[ 80 ]
-ឯតា [ ហ្នឹង និះ នុះ ] អាការន្ត ឥ. ...................................................................................[ 81 ]
-ឯត [ ហ្នឹង និះ នុះ ] អការន្ត នបុំ. ..................................................................................[ 81 ]
-ឥម [ នេះ ] អការន្ត បុំ..........................................................................................................[ 82 ]
-ឥមា [ នេះ ] អាការន្ត ឥ. .......................................................................................................[ 82 ]
-ឥម [ នេះ ] អការន្ត នបុំ. .......................................................................................................[ 83 ]
-អមុ [ ឯណោះ ] ឧការន្ត បុំ. ...................................................................................................[ 84 ]
-អមុ [ ឯណោះ ] ឧការន្ត ឥ. ....................................................................................................[ 84 ]
-អមុ [ ឯណោះ ] ឧការន្ត នបុំ. ................................................................................................[ 85 ]
-កឹ [ អ្វី,ស្អី,អ្នកណា ] បុំ. ......................................................................................................[ 85 ]
-កឹ [ អ្វី,ស្អី,អ្នកណា ] ឥ. .......................................................................................................[ 86 ]
-កឹ [ អ្វី,ស្អី ] នបុំ. .................................................................................................................[ 86 ]
-កឹ សព្វមាន ចិ ខាងចុង [ អ្វីមួយ,ស្អីមួយ,អ្នកន៉ាមួយ ] បុំ. ..........................................[ 87 ]
-កឹ សព្វមាន ចិ ខាងចុង [ អ្វីមួយ,ស្អីមួយ,អ្នកណាមួយ ] ឥ. ......................................[ 87 ]
-កឹ មាន ចិ ខាងចុង [ អ្វីមួយ,ស្អីមួយ,អ្នកន៉ាមួយ ] នបុំ. ..............................................[ 88 ]
-កឹ សព្វមាន យ ខាងដើម ចិ ខាងចុង [ ណានីមួយ,ទាំងអស់ ] បុំ. ..............................[ 88 ]
-កឹ សព្វមាន យ ខាងដើម ចិ ខាងចុង [ ន៉ានីមួយ,ទាំងអស់ ] ឥ. .................................[ 89 ]
-កឹ សព្វមាន យ ខាងដើម ចិ ខាងចុង [ ន៉ានីមួយ,ទាំងអស់ ] នបុំ. .............................[ 89 ]
-ឯក [ មួយ ] បុំ. ......................................................................................................................[ 90 ]
-ឯកា [ មួយ ] ឥ. .....................................................................................................................[ 90 ]
-ឯក [ មួយ ] នបុំ. ...................................................................................................................[ 91 ]

-ឧភ [ ទាំងពីរ ] ត្រៃលិង្គ, ទ្វិ [ ពីរ ] ត្រៃលិង្គ ........................................................[ 91 ]

-តិ [ បី ] បុំ., ឥ, នបុំ. ........................................................................................[ 92 ]

-ចតុ [ បួន ] បុំ. ...............................................................................................[ 92 ]

-ចតុ [ បួន ] ឥ. ...............................................................................................[ 93 ]

-ចតុ [ បួន ] នបុំ. ............................................................................................[ 93 ]

-បញ្ច [ ប្រាំ ] ត្រៃលិង្គ.....................................................................................[ 93 ]

-កតិ [ ប៉ុន្មាន ] ត្រៃលិង្គ.................................................................................[ 93 ]

-វីសតិ [ ២០ ] ឥ. .............................................................................................[ 94 ]

-វីស [ ២០ ] ឥ. ................................................................................................[ 94 ]

-សត [ រយ ] អការន្ត នបុំ....................................................................................[ 95 ]

**៥. អលិង្គនាម**..................................................................................................[ 96 ]

-តុម្ហ [ ព្រះអង្គ, លោក, អ្នក, ឯង ] ត្រៃលិង្គ ...................................................[ 96 ]

-អម្ហ [ អាត្មា, ខ្ញុំ, កូរណា, យើង ] ត្រៃលិង្គ ......................................................[ 96 ]

-ឧបនគរ [ ទីជិតនគរ ] អការន្ត នបុំ. ..................................................................[ 97 ]

-តិលោក [ ត្រៃលោក ] អការន្ត នបុំ. ...................................................................[ 97 ]

**៦. វាក្យសម្ពន្ធ** ( សម្រាប់ទន្ទេញ )......................................................................[ 98 ]

-១. បឋមាវិភត្តិ ( សម្ពន្ធចូលនឹងកិរិយា )..............................................................[ 98 ]

-២. ទុតិយាវិភត្តិ ( សម្ពន្ធចូលនឹងកិរិយា / នាម / អព្យយសព្ទ )..................................[ 98 ]

-៣. តតិយាវិភត្តិ ( សម្ពន្ធចូលនឹងនាម / កិរិយា / និបាត )..........................................[ 99 ]

-៤. ចតុត្ថីវិភត្តិ ( សម្ពន្ធចូលកិរិយា / នាម )..........................................................[ 99 ]

-៥. បញ្ចមីវិភត្តិ ( សម្ពន្ធចូលកិរិយា / នាម )..........................................................[ 100 ]

-៦. ឆដ្ឋីវិភត្តិ ( សម្ពន្ធចូលនាម )......................................................................[ 100 ]

-៧. សត្តមីវិភត្តិ ( សម្ពន្ធចូលនាម / កិរិយា )........................................................[ 100 ]

**៧. សម្ពន្ធតួយ៉ាង**..............................................................................................[ 102 ]

-១. កត្តុវាចកៈ......................................................................................................[ 102 ]

-២. កម្មវាចកៈ......................................................................................................[ 103 ]

-៣. ហេតុកត្តុវាចកៈ..............................................................................................[ 104 ]

-៤. ហេតុកម្មវាចកៈ..............................................................................................[ 105 ]

-៥. ភាវវាចកៈ......................................................................................................[ 107 ]

-អំពីអ្នកនិពន្ធ ....................................................................................................[ 108 ]

-ឯកសារយោង......................................................................................................[ 109 ]

# ពាក្យប្រែរបស់វិភត្តិ

*******

## ប្រែថា

| | | |
|---|---|---|
| ប. | **សិ-យោ** | វី |
| អា. | **សិ-យោ** | បពិត្រ ម្នាល នៃ ហៃ អើយ |
| ទុ. | **អំ-យោ** | នូវ កាន់ ញុំាង អស់ រហូត នឹង ចំពោះ ឲ្យជា ថាជា |
| ត. | **នា-ហិ** | ដោយ ដោយនូវ តាម ខាង គឺ ដែល ត្រូវ, ហេតុ ព្រោះ ព្រោះតែ មាន, ដោយទាំង ដោយមាន ញុំាង នឹង |
| ច. | **ស-នំ** | ដល់ ដើម្បី បម្រុង នឹង ចំពោះ សម្រាប់ |
| មី. | **ស្មា-ហិ** | អំពី ចាក ជាង ហេតុ ព្រោះ ព្រោះតែ |
| ឆ. | **ស-នំ** | នៃ របស់ កាល កាលដែល ជំនុំ ចំណោម នូវ គឺ ដែល ត្រូវ |
| ស. | **ស្មឹ-សុ** | ក្នុង ឰដ៏ ត្រង់ នា នាកាល, កាលបើ នៅ លើ ទៀប ជិត ឯ, ក្បែរ និមិត្ត ជ្បិត បណ្តា ក្នុងចំណោម |

*******

## វិធីទន្ទេញ ៖

បឋមា **សិ-យោ** ប្រែថា វី

អាលបនៈ **សិ-យោ** ប្រែថា បពិត្រ ម្នាល នៃ ហៃ អើយ. ............ទន្ទេញ និង សូត្រ បែបនេះរហូតដល់ចប់ ។

# ១. បុល្លិង្គ

**បុរិស** [ ប្រុស ] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | បុរិសោ | បុរិសា |
| អា. | បុរិស បុរិសា | បុរិសា |
| ទុ. | បុរិសំ | បុរិសេ |
| ត. | បុរិសេន | បុរិសេហិ បុរិសេភិ |
| ច. | បុរិសស្ស | បុរិសានំ |
| មី. | បុរិសា បុរិសស្មា បុរិសម្ហា | បុរិសេហិ បុរិសេភិ |
| ឆ. | បុរិសស្ស | បុរិសានំ |
| ស. | បុរិសេ បុរិសស្មឹ បុរិសម្ហិ | បុរិសេសុ |

**មន** [ចិត្ត] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | មនោ | មនា |
| អា. | មន មនា | មនា |
| ទុ. | មនោ មនំ | មនេ |
| ត. | មនសា មនេន | មនេហិ មនេភិ |
| ច. | មនសោ មនស្ស | មនានំ |
| មី. | មនា មនស្មា មនម្ហា | មនេហិ មនេភិ |
| ឆ. | មនសោ មនស្ស | មនានំ |
| ស. | មនសិ មនេ មនស្មឹ មនម្ហិ | មនេសុ |

## សព្ទបំបែកដូច បុរិស

បោសោ សុរាសុរ នរោរគ នាគ យក្ខា    គន្ធព្ព កិន្នរ មនុស្ស បិសាច បេតា
មាតង្គ ជង្គម តុរង្គ វរាហ សីហា    ព្យគ្ឃច្ឆ កច្ឆប តរច្ឆ មិគស្ស សោណា
អាលោក លោក និលយានិល ចាគ យោគា    វាយាម គាម និគមាគម ធម្ម កាមា
សំឃោយ ឃោស បដិឃាសវ កោធ លោភា    សារម្ភ ថម្ភ មទ មាន បមាទ មក្ខា
បុន្នាគ បូគ បនសាសន ចម្បកម្ពា    ហិន្តាល តាល ពកុលជ្ជុន កឹសុកា ច
មន្ទារ កុន្ទ បុចិមន្ទ ករញ្ជ រុក្ខា    គិជ្ឈោ មយូរ សកុណណ្ឌជ កោញ្ច ហំសា.

* * * * * * *

ពុទ្ធោ ធម្មោ សង្ឃោ មគ្គោ    ខន្ធោ កាយោ កាមោ កប្បោ
មាសោ បក្ខោ យក្ខោ ភក្ខោ    នាគោ មេឃោ ភោគោ យាគោ.
រាគោ ទោសោ មោហោ មានោ    មក្ខោ ថម្ភោ កោធោ លោកោ
ហាសោ វេរោ ទាហោ តេជោ    ឆន្ទោ កាសោ សាសោ រោគោ.
អស្សោ សស្សោ ឥស្សោ សិស្សោ    សីហោ ព្យគ្ឃោ រុក្ខោ សេលោ
ឥន្ទោ សក្កោ ទេវោ គាមោ    ចន្ទោ សូរោ ឱឃោ ទីបោ.
ផស្សោ យញ្ញោ ចាគោ វាទោ    ហត្ថោ បត្តោ ឃោសោ គេធោ
សោមោ យោធោ គច្ឆោ អច្ឆោ    គេហោ មាឡោ អង្គោ សាលោ.
នរោ នគោ មិគោ សសោ    សុណោ ពកោ អជោ ទិជោ
ហយោ គជោ ខរោ សរោ    ទុមោ តលោ បដោ ធជោ.

## សព្ទបំបែកដូច មន

មនោ វចោ វយោ តេជោ    តបោ ចេតោ តមោ យសោ
អយោ បយោ សិរោ ឆន្ទោ    សរោ ឧរោ រហោ អហោ.

# សព្ទបំបែកដូច បុរិស

**បោស** = បុគ្គល, **សុរ** =ទេវតា, **អសុរ** = អសុរ, **នរ** = នរជន, **ឧរគ** = ពស់, **នាគ** = នាគ, **យក្ខ** = យក្ស **គន្ធព្វ** = គន្ធព្វ,  **កិន្នរ** = កិន្នរ, **មនុស្ស** = មនុស្ស, **បិសាច** = បិសាច, **បេត** = ប្រេត, **មាតង្គ** = ដំរី, **ជង្គម** = សត្វ, **តុរង្គ** = សេះ, **វរាហ** = ជ្រូក, **សីហ** = រាជសីហ៍, **ព្យគ្ឃ** = ខ្លា, **អច្ឆ** = ខ្លាឃ្មុំ, **កច្ឆប** = អណ្តើក, **តរច្ឆ** = ឆ្កែព្រៃ, **មិគ** = ក្តាន់, **អស្ស** = សេះ, **សោណ** = ឆ្កែ, **អាលោក** = ពន្លឺ, **លោក** =លោក, **និលយ**= លំនៅ, **អនិល** = ខ្យល់, **ចាគ** = ចាគៈ,  **យោគ** = ការប្រកប សូត្រ, **វាយាម** = ព្យាយាម **គាម** = ភូមិ ស្រុក, **និគម** = ឃុំ និគម សង្កាត់, **អាគម** = ចំណោះ ការចុះតួអក្សរថ្មី គម្ពីរ, **ធម្ម** = ធម៌, **កាម** = កាម, **សំឃ** = សង្ឃ, **ឱឃ** = អន្លង់ ជំនន់,  **ឃោស** = សំឡេងកងរំពង, **បដិឃ** = កំហល់, **អាសវ** = តណ្ហា, **កោធ** = កំហឹង, **លោភ** = លោភៈ, **សារម្ភ** = ការប្រកួតប្រជែង, **ថម្ភ** = សសរ ភាពរឹងរូស, **មទ** = សេចក្តីស្រវឹង, **មាន** = មានះ, **បមាទ** = សេចក្តីធ្វេសប្រហែស, **មក្ខ** = ការរមិលគុណ, **បុន្នាគ** = ខ្ទឹង, **បូគ** =ស្លា, **បនស** = ខ្នុរ, **អសន** = ធ្នង់,  **ចម្បក** = ដើមចម្បា, **អម្ព** = ស្វាយ, **ហិន្តាល** = ទន្សៃ, **តាល** = ត្នោត, **ពកុល** = ពុល, **អជ្ជុន** = ថ្វាន់, **កឹសុក** = រលួស  **មន្ទារ** = ដើមមន្ទារ, **កុន្ទ** = ដើមរុន ដើមភ្លែកខ្លា, **បុចិមន្ទ** = ស្តៅ, **ករញ្ជ** = ដើមទន្លា, **រុក្ខ** = ដើមឈើ, **គិជ្ឈ** = ត្មាត, **មយូរ** = ក្ងោក, **សកុណ** = ចាប, **អណ្ឌជ** = ចាប, **កោញ្ច** = ក្រៀល, **ហំស** = ហង្ស.

* * * * * * * * *

**ពុទ្ធ** = ព្រះពុទ្ធ, **ធម្ម** = ព្រះធម៌ **សង្ឃ** = ព្រះសង្ឃ, **មគ្គ** = ផ្លូវ, **ខន្ធ** = ខន្ធ, **កាយ** = កាយ, **កប្ប** = កប្ប, **មាស** = ខែ, **បក្ខ** =បក្ស, **យក្ខ** = យក្ស, **ភក្ខ** = ចង្ហាន់, **នាគ** = ដំរី ព្រះអរហន្ត **មេឃ** = ពពក, **ភោគ** = ភោគៈ, **យាគ** = ការបូជា, **រាគ** = រាគៈ, **ទោស** = ទោសៈ, **មោហ** = មោហៈ, **ហាស** = សំណើច, **វេរ** = ពៀរ,  **ទាហ** = កម្តៅ ការដុត, **តេជ** = តេជះ អំណាច, **ឆន្ទ** = ឆន្ទៈ បំណង, **កាស** = រោគក្អក, **សាស** = រោគហឺត, **រោគ** = រោគ, **អស្ស** = សេះ, **សស្ស** = សន្ទូង, **ឥស្ស** = ព្រួញ, **សិស្ស** = អ្នករៀន, **ឥន្ទ** = ព្រះឥន្ទ, **សក្ក** = ស្តេចសក្កៈ, **ទេវ** = ទេព្តា, **ចន្ទ** = ព្រះច័ន្ទ, **ទីប** = កោះ, **ផស្ស** = ផស្សៈ, **យញ្ញ** = យញ្ញ,  **វាទ** = វាទៈ, **ហត្ថ** = ដៃ, **បត្ត** = បាត្រ, **គេធ** = ចំណង់, **សោម** = ព្រះច័ន្ទ, **យោធ** = អ្នកចម្បាំង, **គច្ឆ** = គុម្ពឈើ, **គេហ** = ផ្ទះ, **មាឡ** = រោង បារាំ, **អដ្ឋ** = ន័យ សេចក្តី, **សាល** =បងប្អូនថ្លៃ, **នគ** = ភ្នំ, **សស** = ទន្សាយ, **សុណ** = ឆ្កែ, **ពក** = កុក, **អជ** = ពពែ, **ទិជ** = ចាប ព្រាហ្មណ៍ ធ្មេញ, **ហយ** = សេះ , **ខរ** = សត្វលា, **សរ** = ស្រះ, **ទុម** = ដើមឈើ, **តល** = ផ្ទៃ បាត, **បជ** = ក្រណាត់,  **ធជ** = ទង់ ។

## សព្ទបំបែកដូច មន សព្ទ

**មន** = ចិត្ត, **វច** = វាចា, **វយ** = ខ្យល់, **តេជ** = ភ្លើង, **តប** = សេចក្តីប្រឹងប្រែង, **ចេត** = សេចក្តីតាំងចិត្ត, **តម** = សេចក្តីងងឹត, **យស** = យស, **អយ** = ដែក, **បយ** = ទឹកដោះ, **សិរ** = ក្បាល, **ឆន្ទ** = ឆន្ទ (គម្ពីរឆន្ទ) **សរ** = ស្រះ, **ឧរ** = ទ្រូង, **រហ** = ទីកំបាំង, **អហ** = ថ្ងៃ ។

* * * * * * * *

**បទមាលា** បានដល់ លំដាប់បទដែលចុះវិភត្តិហើយ ប្រែតាមសព្ទថា “ **កម្រងនៃបទ** ” មានសេចក្តីប្រៀបធៀប ថា បទ ប្រៀបដូច ផ្កា, វិភត្តិ ប្រៀបដូច ខ្សែ, ការផ្សំរូបសព្ទប្រៀបដូចពណ៌ និង ន័យរបស់បទ ប្រៀបដូចក្លិន ។

### កុំមើលងាយប្រាជ្ញាខ្លួនឯង

**អប្បកំ នាតិមញ្ញេយ្យ, ចិត្តេ សុតំ និធាបយេ;**
**វម្មិកោទកពិន្ទូវ, ចិរេន បរិបូរតិ.**

កុំមើលងាយថាបញ្ញាតិច រៀនទៅក្រែងភ្លេចមិនចម្រើន
សុតមយប្បញ្ញាបើក្រវើន យូរទៅគង់ច្រើនពេញហឫទ័យ
ដូចក្អមដំកល់លើដំបូក ភ្លៀងអុរជោក ៗ អចិន្ត្រៃយ៍
តំណក់តក់ៗតែរាល់ថ្ងៃ អាស្រ័យយូរទៅគង់ពេញបាន ។

(លោកនីតិ គាថាទី ៥)

**អាប** [ទឹក] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អាបោ | អាបា |
| អា. | អាប អាបា | អាបា |
| ទុ. | អាបោ អាបំ | អាបេ |
| ត. | អាបេន | អាបេហិ អាបេភិ |
| ច. | អាបស្ស | អាបានំ |
| មី. | អាបា អាបស្មា អាបម្ហា | អាបេហិ អាបេភិ |
| ឆ. | អាបស្ស | អាបានំ |
| ស. | អាបេ អាបស្មឹ អាបម្ហិ | អាបេសុ |

**ថាម** [កម្លាំង] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ថាមោ | ថាមា |
| អា. | ថាម ថាមា | ថាមា |
| ទុ. | ថាមំ | ថាមេ |
| ត. | ថាមសា ថាមេន ថាមុនា | ថាមេហិ ថាមេភិ |
| ច. | ថាមសោ ថាមស្ស ថាមុនោ | ថាមានំ |
| មី. | ថាមា ថាមស្មា ថាមម្ហា ថាមុនា | ថាមេហិ ថាមេភិ |
| ឆ. | ថាមសោ ថាមស្ស ថាមុនោ | ថាមានំ |
| ស. | ថាមសិ ថាមេ ថាមស្មឹ ថាមម្ហិ | ថាមេសុ |

**សរទោ** សរទរដូវ, **វាយោ** ខ្យល់,**រជោ** ធូលី បំបែក ដូច **អាបោ** ។

**គុណវន្តុ** [អ្នកដ៏មានគុណ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | **ឯក.** | **ពហុ.** |
|---|---|---|
| ប. | គុណវា | គុណវន្តោ គុណវន្តា |
| អា. | គុណវំ គុណវ គុណវា | គុណវន្តោ គុណវន្តា |
| ទុ. | គុណវន្តំ | គុណវន្តេ |
| ត. | គុណវតា គុណវន្តេន | គុណវន្តេហិ គុណវន្តេភិ |
| ច. | គុណវន្តស្ស  គុណវតោ | គុណវតំ  គុណវន្តានំ |
| មី. | គុណវតា គុណវន្តា គុណវន្តស្មា គុណវន្តម្ហា | គុណវន្តេហិ គុណវន្តេភិ |
| ឆ. | គុណវន្តស្ស  គុណវតោ | គុណវតំ គុណវន្តានំ |
| ស. | គុណវតិ គុណវន្តេ គុណវន្តស្មឹ គុណវន្តម្ហិ | គុណវន្តេសុ |

សព្ទបំបែក **គុណវន្តុ**

គណវា,កុលវា,ពលវា,យសវា,ធនវា,សុតវា,ភគវា,ហិមវា, ផលវា,សីលវា,បញ្ញវា,ធិតិមា,គតិមា,មតិមា, មុតិមា,មុត្តិមា,ជុតិមា,សិរិមា,ហិរិមា,ថុតិមា,រតិមា,យតិមា,សុចិមា,កលិមា,ពលិមា, កសិមា,រុចិមា,ពុទ្ធិមា,ចក្ខុមា,ពន្ធុមា,ហេតុមា,សេតុមា,កេតុមា,រាហុមា,ភាណុមា,ខាណុមា,វិជ្ជុមា ។

**គណវា** = ដែលមានពួក, **ពលវា** = ដែលមានកម្លាំង, **យសវា** = ដែលមានយស, **ធនវា** = ដែលមានលុយ, **សុតវា** = ដែលមានការសិក្សា, **ភគវា** = ព្រះដ៏មានព្រះភាគជាម្ចាស់, **ហិមវា** = ដែលមានទឹកកក, **ផលវា** = ដែលមានផល, **សីលវា** = ដែលមានសីល, **បញ្ញវា** = ដែលមានប្រាជ្ញា, **ធិតិមា** = ដែលមានសេចក្ដីមុតមាំ, **គតិមា** = ដែលមានគតិ, **មតិមា** = ដែលមានប្រាជ្ញា, **មុតិមា** = ដែលមានប្រាជ្ញា, **មុត្តិមា** = ដែលមានសេចក្ដីរួចផុត, **ជុតិមា** = ដែលមានរស្មី, **សិរិមា** = ដែលមានសិរីមង្គល, **ហិរិមា** = ដែលមានហិរិ, **ថុតិមា** = ដែលមានសេចក្ដីសរសើរ, **រតិមា** = ដែលមានសេចក្ដីត្រេកអរ, **យតិមា** = ដែលមានសេចក្ដីសំរួម, **សុចិមា** = ដែលមានសេចក្ដីស្អាត, **កលិមា** = ដែលមានទោស, **ពលិមា** = ដែលមានពលី, **កសិមា** = ដែលមានកសិកម្ម, **រុចិមា** = ដែលមានរស្មី, **ពុទ្ធិមា** = ដែលមានពុទ្ធិ, **ចក្ខុមា** = ដែលមានចក្ខុ, **ពន្ធុមា** = ដែលមានបក្សពួក, **ហេតុមា** = ដែលមានហេតុ, **សេតុមា** = ដែលមានហេតុ ដែលមានស្ពាន, **កេតុមា** = ដែលមានទង់, **រាហុមា** = ដែលមានរាហូ, ព្រះច័ន្ទ, **ភាណុមា** = ដែលមានពន្លឺ, ព្រះអាទិត្យ, **ខាណុមា** = ដែលមានដង្កត់, **វិជ្ជុមា** = ដែលមានផ្លេកបន្ទោរ ។

**ហិមវន្តុ** [ដែលមានទឹកកក] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ហិមវន្តោ ហិមវា | ហិមវន្តោ ហិមវន្តា |
| អា. | ហិមវំ  ហិមវ ហិមវា | ហិមវន្តោ ហិមវន្តា |
| ទុ. | ហិមវន្តំ | ហិមវន្តេ |
| ត. | ហិមវតា ហិមវន្តេន | ហិមវន្តេហិ ហិមវន្តេភិ |
| ច. | ហិមវន្តស្ស  ហិមវតោ | ហិមវតំ ហិមវន្តានំ |
| មី. | ហិមវតា ហិមវន្តា ហិមវន្តស្មា  ហិមវន្តម្ហា | ហិមវន្តេហិ ហិមវន្តេភិ |
| ឆ. | ហិមវន្តស្ស  ហិមវតោ | ហិមវតំ ហិមវន្តានំ |
| ស. | ហិមវតិ ហិមវន្តេ ហិមវន្តស្មឹ  ហិមវន្តម្ហិ | ហិមវន្តេសុ |

**សតិមន្តុ** [ដែលមានសតិ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សតិមន្តោ សតិមា | សតិមន្តោ សតិមន្តា |
| អា. | សតិមំ សតិម សតិមា | សតិមន្តោ សតិមន្តា |
| ទុ. | សតិមំ សតិមន្តំ | សតិមន្តេ |
| ត. | សតិមតា សតិមន្តេន | សតិមន្តេហិ សតិមន្តេភិ |
| ច. | សតិមន្តស្ស  សតិមស្ស សតិមតោ | សតិមតំ សតិមន្តានំ |
| មី. | សតិមតា សតិមន្តា សតិមន្តស្មា សតិមន្តម្ហា | សតិមន្តេហិ សតិមន្តេភិ |
| ឆ. | សតិមន្តស្ស  សតិមស្ស សតិមតោ | សតិមតំ  សតិមន្តានំ |
| ស. | សតិមតិ សតិមន្តេ សតិមន្តស្មឹ សតិមន្តម្ហិ | សតិមន្តេសុ |

**ពន្ធុមន្តុ** បំបែកដូច **សតិមន្តុ** ។

សទ្ទនីតិ បទមាលា ប្រាប់ ថា អ្នកវ្យាករណ៍ជាច្រើន ចាត់ទុក **មឃវ** សព្ទ  បំបែកដូច យុវ គឺ មាន រូប ថា *មឃវា, មឃវា, មឃវានោ មឃវានា* ជាដើម ប៉ុន្តែក្នុងនិរុត្តិបិដកនិងចូឡនិរុត្តិ មានរូបបំបែកដូច **គុណវា** សព្ទ ដូចទៅនេះ

**មឃវន្តុ** [ស្តេចសក្កៈដែលមានឈ្មោះថា មឃៈ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | មឃវា | មឃវន្តោ |
| អា. | មឃវា | មឃវន្តោ |
| ទុ. | មឃវន្តំ | មឃវន្តេ |
| ត. | មឃវតា | មឃវន្តេហិ មឃវន្តេភិ |
| ច. | មឃវតោ | មឃវន្តានំ |
| មី. | មឃវតា | មឃវន្តេហិ មឃវន្តេភិ |
| ឆ. | មឃវតោ | មឃវន្តានំ |
| ស. | មឃវតិ | មឃវន្តេសុ |

**មឃ** + **វន្តុ** = **មឃវន្តុ** ដែលមានឈ្មោះថា មឃៈ  វិ. **មឃោតិ នាមំ អស្ស អត្ថីតិ មឃវា** ។ **នាមំ** រឺឈ្មោះ, **មឃោ ឥតិ** ថា មឃៈ, **អស្ស សក្កស្ស** របស់ស្តេចសក្កៈនោះ, **អត្ថិ** មាន, **ឥតិ** ព្រោះហេតុនោះ, **សោ សក្កោ** រឺស្តេចសក្កៈនោះ, **មឃវា** ឈ្មោះថា **មឃវា** ។ ស្តេចសក្កៈធ្លាប់កើតជាមនុស្ស ឈ្មោះថា  **មឃៈ** នៅពេលស្លាប់ហើយ ក៏កើតជាព្រះឥន្ទ ហេតុនោះ ព្រះឥន្ទនោះ ទើបបានឈ្មោះថា **មឃវា** ។

ម្យ៉ាងទៀត គម្ពីរដីកា ប្រាប់ ថា មឃ បានដល់ ទ្រព្យ គឺ សទ្ធា ហ្នឹងឯង ។

**មឃំ វុច្ចតិ ធនំ, តំ បន សទ្ធាសង្ខាតំ មឃំ អស្ស អត្ថីតិ មឃវា** ។ ទ្រព្យ ហៅថា មឃៈ ចំណែកព្រះឥន្ទ ឈ្មោះថា មឃវា ព្រោះជាអ្នកមានទ្រព្យគឺសទ្ធានោះ ។

**គច្ឆន្ត** [កាលទៅ កំពុងទៅ] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គច្ឆំ គច្ឆន្តោ | គច្ឆន្តោ គច្ឆន្តា |
| អា. | គច្ឆំ គច្ឆ គច្ឆា | គច្ឆន្តោ គច្ឆន្តា |
| ទុ. | គច្ឆន្តំ | គច្ឆន្តេ |
| ត. | គច្ឆតា គច្ឆន្តេន | គច្ឆន្តេហិ គច្ឆន្តេភិ |
| ច. | គច្ឆតោ គច្ឆន្តស្ស | គច្ឆតំ គច្ឆន្តានំ |
| មី. | គច្ឆតា គច្ឆន្តា គច្ឆន្តស្មា គច្ឆន្តម្ហា | គច្ឆន្តេហិ គច្ឆន្តេភិ |
| ឆ. | គច្ឆតោ គច្ឆន្តស្ស | គច្ឆតំ គច្ឆន្តានំ |
| ស. | គច្ឆតិ គច្ឆន្តេ គច្ឆន្តស្មឹ គច្ឆន្តម្ហិ | គច្ឆន្តេសុ |

**សព្ទបំបែកដូច គច្ឆន្ត**

គច្ឆំ មហំ ចរំ តិដ្ឋំ ទទំ ភុញ្ជំ សុណំ បចំ

ជយំ ជីរំ ចវំ មីយំ សរំ កុព្ពំ ជបំ វជំ.

**គច្ឆំ** = កំពុងទៅ, **មហំ** = កំពុងបូជា ធំ, **ចរំ** = កំពុងត្រាច់ទៅ, **តិដ្ឋំ** = កំពុងឈរ, **ទទំ** = កំពុងឲ្យ, **ភុញ្ជំ** = កំពុងបរិភោគ, **សុណំ** = កំពុងស្តាប់, **បចំ** = កំពុងចម្អិន, **ជយំ** = កំពុងឈ្នះ, **ជីរំ** = កំពុងចាស់, **ចវំ** = កំពុងច្យុត, **មីយំ** = កំពុងស្លាប់, **សរំ** = កំពុងរលឹក, **កុព្ពំ** = កំពុងធ្វើ, **ជបំ** = កំពុងសូធ្យ, **វជំ** = កំពុងទៅ

* * * * * * * *

**ភវន្ត** [អ្នកដ៏ចម្រើន] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ភវំ | ភោន្តោ ភវន្តោ ភវន្តា |
| អា. | ភោ ភន្តេ ភោន្ត ភោន្តា | ភោន្តោ ភវន្តោ ភវន្តា |
| ទុ. | ភវន្តំ | ភោន្តេ ភវន្តេ |
| ត. | ភោតា ភវតា ភវន្តេន | ភវន្តេហិ ភវន្តេភិ |
| ច. | ភោតោ ភវតោ ភវន្តស្ស | ភវតំ ភវន្តានំ |
| មី. | ភោតា ភវតា  ភវន្តា ភវន្តស្មា ភវន្តម្ហា | ភវន្តេហិ ភវន្តេភិ |
| ឆ. | ភោតោ ភវតោ ភវន្តស្ស | ភវតំ ភវន្តានំ |
| ស. | ភវតិ ភវន្តេ ភវន្តស្មឹ ភវន្តម្හិ | ភវន្តេសុ |

**ភទន្ត** [លោកដ៏ចម្រើន] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ភទន្តោ | ភទ្ទន្តា ភទន្តា |
| អា. | ភទ្ទន្ត ភទ្ទន្តេ  ភន្តេ ភទន្ត ភទន្តា | ភទ្ទន្តា ភន្តេ ភទន្តា |
| ទុ. | ភទន្តំ | ភទ្ទន្តេ ភទន្តេ |
| ត. | ភទន្តេន | ភទន្តេហិ ភទន្តេភិ |
| ច. | ភទន្តស្ស | ភទន្តានំ |
| មី. | ភទន្តា ភទន្តស្មា ភទន្តម្ហា | ភទន្តេហិ ភទន្តេភិ |
| ឆ. | ភទន្តស្ស | ភទន្តានំ |
| ស. | ភទន្តេ ភទន្តស្មឹ ភទន្តម្හិ | ភទន្តេសុ |

**សន្ត** [កាលមាន,កំពុងមាន, សប្បុរស] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សំ សន្តោ | សន្តោ សន្តា |
| អា. | សំ ស សា | សន្តោ សន្តា |
| ទុ. | សន្តំ | សន្តេ |
| ត. | សតា សន្តេន | សន្តេហិ សព្ភិ |
| ច. | សតោ សន្តស្ស | សតំ សន្តានំ |
| មី. | សតា សន្តា សន្តស្មា សន្តម្ហា | សន្តេហិ សព្ភិ |
| ឆ. | សតោ សន្តស្ស | សតំ សន្តានំ |
| ស. | សតិ សន្តេ សន្តស្មឹ សន្តម្ហិ | សន្តេសុ |

**រាជ** [ព្រះរាជា,ស្តេច] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | រាជា | រាជានោ |
| អា. | រាជ រាជា | រាជានោ |
| ទុ. | រាជានំ រាជំ | រាជានោ |
| ត. | រញ្ញា រាជេន | រាជូហិ រាជូភិ រាជេហិ រាជេភិ |
| ច. | រញ្ញោ រាជិនោ | រញ្ញំ រាជូនំ រាជានំ |
| មី. | រញ្ញា | រាជូហិ រាជូភិ រាជេហិ រាជេភិ |
| ឆ. | រញ្ញោ រាជិនោ | រញ្ញំ រាជូនំ រាជានំ |
| ស. | រញ្ញេ រាជិនិ | រាជូសុ រាជេសុ |

**ព្រហ្ម** [ព្រហ្ម] អការន្ត បុំ. បំបែក ដូច្នេះ

| | **ឯក.** | **ពហុ.** |
|---|---|---|
| ប. | ព្រហ្មា | ព្រហ្មានោ |
| អា. | ព្រហ្មេ | ព្រហ្មានោ |
| ទុ. | ព្រហ្មានំ ព្រហ្មំ | ព្រហ្មានោ |
| ត. | ព្រហ្មុនា | ព្រហ្មេហិ ព្រហ្មេភិ |
| ច. | ព្រហ្មុនោ ព្រហ្មស្ស | ព្រហ្មានំ ព្រហ្មូនំ |
| មី. | ព្រហ្មុនា | ព្រហ្មេហិ ព្រហ្មេភិ |
| ឆ. | ព្រហ្មុនោ ព្រហ្មស្ស | ព្រហ្មានំ ព្រហ្មូនំ |
| ស. | ព្រហ្មនិ | ព្រហ្មេសុ |

**អត្ត** [ខ្លួន] អការន្ត បុំ. បំបែក ដូច្នេះ

| | **ឯក.** | **ពហុ.** |
|---|---|---|
| ប. | អត្តា | អត្តានោ |
| អា. | អត្ត អត្តា | អត្តានោ |
| ទុ. | អត្តានំ អត្តំ | អត្តានោ |
| ត. | អត្តនា អត្តេន | អត្តនេហិ អត្តនេភិ |
| ច. | អត្តនោ | អត្តានំ |
| មី. | អត្តនា | អត្តនេហិ អត្តនេភិ |
| ឆ. | អត្តនោ | អត្តានំ |
| ស. | អត្តនិ | អត្តេសុ |

**សខ** [សម្លាញ់] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សខា | សខានោ សខាយោ សខិនោ |
| អា. | សខ សខា សខិ សខី សខេ | សខានោ សខាយោ សខិនោ |
| ទុ. | សខារំ  សខានំ សខំ | សខានោ សខាយោ សខិនោ |
| ត. | សខិនា | សខារេហិ-សខារេភិ សខេហិ-សខេភិ |
| ច. | សខិនោ សខិស្ស | សខារានំ សខីនំ |
| មី. | សខិនា | សខារេហិ-សខារេភិ សខេហិ-សខេភិ |
| ឆ. | សខិនោ សខិស្ស | សខារានំ សខីនំ |
| ស. | សខេ | សខារេសុ សខេសុ |

**អាតុម** [ខ្លួន] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អាតុមា | អាតុមានោ |
| អា. | អាតុម អាតុមា | អាតុមានោ |
| ទុ. | អាតុមានំ អាតុមំ | អាតុមានោ |
| ត. | អាតុមេន | អាតុមេហិ អាតុមេភិ |
| ច. | អាតុមស្ស | អាតុមានំ |
| មី. | អាតុមា អាតុមស្មា អាតុមម្හា | អាតុមេហិ អាតុមេភិ |
| ឆ. | អាតុមស្ស | អាតុមានំ |
| ស. | អាតុមេ អាតុមស្មឹ  អាតុមម្හិ | អាតុមេសុ |

**បុម** [ប្រុស] អការន្ត បុំ. បំបែក ដូច្នេះ

| | **ឯក.** | **ពហុ.** |
|---|---|---|
| ប. | បុមា | បុមានោ |
| អា. | បុមំ | បុមានោ |
| ទុ. | បុមំ | បុមានោ |
| ត. | បុមានា បុមុនា បុមេន | បុមានេហិ-បុមានេភិ បុមេហិ-បុមេភិ |
| ច. | បុមុនោ បុមស្ស | បុមានំ |
| មី. | បុមានា បុមុនា បុមា បុមស្មា បុមម្ហា | បុមានេហិ-បុមានេភិ បុមេហិ-បុមេភិ |
| ឆ. | បុមុនោ បុមស្ស | បុមានំ |
| ស. | បុមានេ បុមេ បុមស្មឹ បុមម្ហិ | បុមាសុ បុមេសុ |

**យុវ** [ កម្លោះ ] អការន្ត បុំ. បំបែក ដូច្នេះ

| | **ឯក.** | **ពហុ.** |
|---|---|---|
| ប. | យុវា យុវានោ | យុវានា យុវា |
| អា. | យុវ យុវា យុវាន  យុវានា | យុវានា យុវា |
| ទុ. | យុវានំ យុវំ | យុវានេ យុវេ |
| ត. | យុវានា យុវេន យុវានេន | យុវានេហិ-យុវានេភិ យុវេហិ-យុវេភិ |
| ច. | យុវានស្ស យុវស្ស | យុវានានំ យុវានំ |
| មី. | យុវានា យុវានស្មា  យុវានម្ហា | យុវានេហិ-យុវានេភិ យុវេហិ-យុវេភិ |
| ឆ. | យុវានស្ស យុវស្ស | យុវានានំ យុវានំ |
| ស. | យុវានេ យុវានស្មឹ យុវានម្ហិ យុវេ យុវស្មឹ យុវម្ហិ | យុវានេសុ យុវាសុ យុវេសុ |

**សា** [ ឆ្កែ ] អាការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សា | សា |
| អា. | ស សា | សា |
| ទុ. | សំ | សេ |
| ត. | សេន | សាហិ សាភិ |
| ច. | សស្ស សាយ | សានំ |
| មី. | សា សស្មា សម្ហា | សាហិ សាភិ |
| ឆ. | សស្ស | សានំ |
| ស. | សេ សស្មឹ សម្ហិ | សាសុ |

**បច្ចក្ខធម្មា** ធម៌ប្រត្យក្ស, **គាណ្ឌីវធន្វា** អ្នកមានធ្នូដែលមានថ្នាំងច្រើន

**អគ្គិ** [ ភ្លើង ] ឥការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អគ្គិនិ អគ្គិ | អគ្គី អគ្គយោ |
| អា. | អគ្គិ | អគ្គី អគ្គយោ |
| ទុ. | អគ្គឹ | អគ្គី អគ្គយោ |
| ត. | អគ្គិនា | អគ្គីហិ-អគ្គីភិ អគ្គិហិ-អគ្គិភិ |
| ច. | អគ្គិនោ អគ្គិស្ស | អគ្គីនំ អគ្គិនំ |
| មី. | អគ្គិនា អគ្គិស្មា អគ្គិម្ហា | អគ្គីហិ-អគ្គីភិ អគ្គិហិ-អគ្គិភិ |
| ឆ. | អគ្គិនោ អគ្គិស្ស | អគ្គីនំ អគ្គិនំ |
| ស. | អគ្គិស្មឹ អគ្គិម្ហិ | អគ្គីសុ អគ្គិសុ |

## សព្ទបំបែកដូច អគ្គិ

ជោតិ បាណិ គណ្ឋិ មុដ្ឋិ    កុច្ឆិ វត្ថិ សាលិ វីហិ
ព្យាធិ ឱធិ ពោធិ សន្ធិ    រាសិ កេសិ សាតិ ទីបិ.

ឥសិ មុនិ មណិ ធនិ យតិ គិរិ រវិ កវិ,
កបិ អសិ មសិ និធិ វិធិ អហិ កិមិ បតិ
ហរិ អរិ តិមិ កលិ ពលិ ជលធិ គហបតិ,
ឧរុធិតិ វរមតិ និរុបធិ អធិបតិ.
អញ្ជលិ សារថិ អតិថិ សមាធិ ឧទធិប្បភុតយោ.

**ជោតិ** = ភ្លើង, **បាណិ** = បាតដៃ, **គណ្ឋិ** = សព្ទពិបាក គន្លាក់, **មុដ្ឋិ** = កណ្ដាប់ដៃ, **កុច្ឆិ** = ផ្ទៃ, **វត្ថិ** = ប្លោកនោម, **សាលិ** = ស្រូវសាលី, **វីហិ** = ស្រូវ, **ព្យាធិ** = ជំងឺ, **ឱធិ** = ព្រំដែន, **ពោធិ** =ដើមពោធិ៍, **សន្ធិ** = ការតភ្ជាប់, **រាសិ** = គំនរ, **កេសិ** = បុរសឈ្មោះកេសិ, **សាតិ** = បុរសឈ្មោះសាតិ, **ទីបិ** = ខ្លាដំបង, **ឥសិ** = ឥសី, **មុនិ** = មុនី, **មណិ** = កែវមណី, **ធនិ** = សំឡេង, **យតិ** = ភិក្ខុ, **គិរិ** = ភ្នំ, **រវិ** = ព្រះអាទិត្យ, **កវិ** = កវី, **កបិ** = ស្វា, **អសិ** = ដាវ, **មសិ** = ទឹកមឹក (ទឹកសរសេរ), **និធិ** = កំណប់ទ្រព្យ, **វិធិ** = វិធី ពិធី, **អហិ** = ពស់, **កិមិ** = ដង្កូវ, **បតិ** = ប្ដី ម្ចាស់, **ហរិ** = ព្រះនារាយណ៍, **អរិ** = សត្រូវ, **តិមិ** = ត្រីតិមិ, **កលិ** = បាប, **ពលិ** = ពលីកម្ម, **ជលធិ** = មហាសមុទ្រ, **គហបតិ** = គហបតី, **ឧរុធិតិ** = អ្នកមានសេចក្ដីព្យាយាមខ្លាំង, **វរមតិ** = អ្នកមានមតិល្អ, **និរុបធិ** = អ្នកមិនមានឧបធិ, **អធិបតិ** = អធិបតី, **អញ្ជលិ** = ក្រពុំប្រមដៃ, **សារថិ** = អ្នកបើកបរ, **អតិថិ** = ភ្ញៀវ, **សមាធិ** = សមាធិ, **ឧទធិ** = មហាសមុទ្រ, **សេដ្ឋិ** = សេដ្ឋី, **ចក្កវត្តិ** = ចក្រពត្តិ

<u>ស្វែងប្រាជ្ញ</u>

**បណ្ឌិតោ សុតសម្បន្នោ,    យត្ថ អត្ថីតិ ចេ សុតោ;**
**មហុស្សាហេន តំ ឋានំ,    គន្តព្ពំវ សុតេសិនា.**

បើឮថាមានអ្នកប្រាជ្ញច្បាស់    កបសូត្រសិល្បសាស្ត្រក្នុងទីណា
អ្នកស្វែងរៀនសូត្យខំឧស្សាហ៍    យាត្រាចូលទៅទីនោះហោង ។

(លោកនីតិ គាថាទី ៨)

**ទណ្ឌី** [ អ្នកមានឈើច្រត់ ] ឦការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ទណ្ឌី | ទណ្ឌី ទណ្ឌិនោ |
| អា. | ទណ្ឌិ | ទណ្ឌី ទណ្ឌិនោ |
| ទុ. | ទណ្ឌិនំ ទណ្ឌឹ | ទណ្ឌី ទណ្ឌិនោ |
| ត. | ទណ្ឌិនា | ទណ្ឌីហិ ទណ្ឌីភិ |
| ច. | ទណ្ឌិនោ ទណ្ឌិស្ស | ទណ្ឌីនំ |
| មី. | ទណ្ឌិនា ទណ្ឌិស្មា ទណ្ឌិម្ហា | ទណ្ឌីហិ ទណ្ឌីភិ |
| ឆ. | ទណ្ឌិនោ ទណ្ឌិស្ស | ទណ្ឌីនំ |
| ស. | ទណ្ឌិនិ ទណ្ឌិស្មឹ ទណ្ឌិម្ហិ | ទណ្ឌីសុ |

**ភិក្ខុ** [ ភិក្ខុ ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ភិក្ខុ | ភិក្ខូ ភិក្ខវោ |
| អា. | ភិក្ខុ | ភិក្ខូ ភិក្ខវេ ភិក្ខវោ |
| ទុ. | ភិក្ខុំ | ភិក្ខូ ភិក្ខវោ |
| ត. | ភិក្ខុនា | ភិក្ខូហិ-ភិក្ខូភិ ភិក្ខុហិ-ភិក្ខុភិ |
| ច. | ភិក្ខុនោ ភិក្ខុស្ស | ភិក្ខូនំ ភិក្ខុនំ |
| មី. | ភិក្ខុនា ភិក្ខុស្មា ភិក្ខុម្ហា | ភិក្ខូហិ-ភិក្ខូភិ ភិក្ខុហិ-ភិក្ខុភិ |
| ឆ. | ភិក្ខុនោ ភិក្ខុស្ស | ភិក្ខូនំ ភិក្ខុនំ |
| ស. | ភិក្ខុស្មឹ ភិក្ខុម្ហិ | ភិក្ខូសុ ភិក្ខុសុ |

## សព្ទបំបែកដូច ទណ្ឌី

ធម្មី សំឃី ញាណី ហត្ថី ចក្កី បក្ខី ទាឋី រដ្ឋី
ឆត្តី មាលី វម្មី យោគី ភាគី ភោគី កាមី សាមី.
ធជី គណី សសី កុដ្ឋី ជដី យានី សុខី សិខី
ទន្តី មន្តី ករី ចាគី កុសលី មុសលី ពលី.
បាបការី សត្តុឃាតី មាល្យការី ទីឃជីវី
ធម្មចារី សីឃយាយី សីហនាទី ភូមិសាយី.

## សព្ទបំបែកដូច ភិក្ខុ

សេតុ កេតុ រាហុ ភានុ, បង្គុ ឧច្ឆុ វេឡុ មច្ចុ, សិន្ធុ ពន្ធុ នេរុ មេរុ, សត្តុ ការុ ហេតុ ជន្តុ រុរុ បដុ

* * * * * * * *

**ធម្មី** = អ្នកមានធម៌, **សំឃី** = អ្នកមានពួក, **ញាណី** = អ្នកមានញាណ, **ហត្ថី** = ដំរី, **ចក្កី** = ព្រះវិស្ណុ, **បក្ខី** = បក្សី, **ទាឋី** = អ្នកមានចង្កូម, **រដ្ឋី** = អ្នកមានរដ្ឋ ព្រះរាជា, **ឆត្តី** = អ្នកមានឆត្រ, **មាលី** = អ្នកមានកម្រងផ្កា, **វម្មី** = អ្នកមានអាវក្រោះ, **យោគី** = យោគាវចរ, **ភាគី** = អ្នកមានចំណែក, **ភោគី** = អ្នកបរិភោគ អ្នកប្រើប្រាស់, **កាមី** = អ្នកមានតម្រូវការ, **សាមី** = ស្វាមី ចៅហ្វាយ, **ធជី** = អ្នកមានទង់, **គណី** = អ្នកមានពួក, **សសី** = ដួងច័ន្ទ, **កុដ្ឋី** = អ្នកមានរោគឃ្លង់, **ជដី** = អ្នកមានផ្នួងសក់, **យានី** = អ្នកមានយាន, **សុខី** = អ្នកមានសេចក្ដីសុខ, **សិខី** = ក្ងោក, **ទន្តី** = ដំរី, **មន្តី** = មន្ត្រី, **ករី** = ដំរី, **ចាគី** = អ្នកមានចាគៈ អ្នកលះបង់, **កុសលី** = អ្នកមានកុសល, **មុសលី** = អ្នកមានអង្រែ, **ពលី** = អ្នកមានកម្លាំង, **បាបការី** = អ្នកធ្វើបាប, **សត្តុឃាតី** = អ្នកពិឃាតសត្រូវ, **មាល្យការី** = អ្នកក្រងផ្កា, **ទីឃជីវី** = អ្នកមានអាយុវែង, **ធម្មចារី** = អ្នកប្រព្រឹត្តធម៌, **សីឃយាយី** = អ្នកទៅលឿន, **សីហនាទី** = អ្នកបន្លឺសីហនាទ, **ភូមិសាយី** = អ្នកដេកលើដី ។

* * * * * * * *

**សេតុ** = ស្ពាន, **កេតុ** = ទង់, **រាហុ** = រាហូ, **ភានុ** = ព្រះអាទិត្យ រស្មី, **បង្គុ** = មនុស្សខ្វិន, **អច្ឆុ** = អំពៅ, **វេឡុ** = ឫស្សី, **មច្ចុ** = សេចក្ដីស្លាប់ ម្រឹត្យូវ, **សិន្ធុ** = ស្ទឹង, **ពន្ធុ** = ញាតិ បក្សពួក គ្នីគ្នា, **នេរុ** = ភ្នំសុមេរុ, **មេរុ** = ភ្នំព្រះសុមេរុ, **សត្តុ** = សត្រូវ, **ការុ** = ជាង វិស្វករ, **ហេតុ** = ហេតុ, **ជន្តុ** = សត្វ, **រុរុ** = ក្ដាន់មាស, **បដុ** = មនុស្សឆ្លាត

**ហេតុ** [ ហេតុ ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ហេតុ | ហេតូ ហេតវោ ហេតុយោ |
| អា. | ហេតុ | ហេតូ ហេតវេ ហេតវោ |
| ទុ. | ហេតុំ | ហេតូ ហេតវោ ហេតុយោ |
| ត. | ហេតុនា | ហេតូហិ-ហេតូភិ ហេតុហិ-ហេតុភិ |
| ច. | ហេតុនោ ហេតុស្ស | ហេតូនំ ហេតុនំ |
| មី. | ហេតុនា ហេតុស្មា ហេតុម្ហា | ហេតូហិ-ហេតូភិ ហេតុហិ-ហេតុភិ |
| ឆ. | ហេតុនោ ហេតុស្ស | ហេតូនំ ហេតុនំ |
| ស. | ហេតុស្មឹ ហេតុម្ហិ | ហេតូសុ ហេតុសុ |

**ជន្តុ** [ សត្វ ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ជន្តុ | ជន្តូ ជន្តវោ ជន្តុនោ ជន្តុយោ |
| អា. | ជន្តុ | ជន្តូ ជន្តវេ ជន្តវោ |
| ទុ. | ជន្តុំ | ជន្តូ ជន្តវោ ជន្តុនោ ជន្តុយោ |
| ត. | ជន្តុនា | ជន្តូហិ-ជន្តូភិ ជន្តុហិ-ជន្តុភិ |
| ច. | ជន្តុនោ ជន្តុស្ស | ជន្តូនំ ជន្តុនំ |
| មី. | ជន្តុនា ជន្តុស្មា ជន្តុម្ហា | ជន្តូហិ-ជន្តូភិ ជន្តុហិ-ជន្តុភិ |
| ឆ. | ជន្តុនោ ជន្តុស្ស | ជន្តូនំ ជន្តុនំ |
| ស. | ជន្តុសឹ ជន្តុម្ហិ | ជន្តូសុ ជន្តុសុ |

**សត្ថុ** [ ព្រះសាស្តា ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សត្ថា | សត្ថារោ |
| អា. | សត្ថ សត្ថា | សត្ថារោ |
| ទុ. | សត្ថារំ | សត្ថារេ សត្ថារោ |
| ត. | សត្ថារា សត្ថុនា | សត្ថារេហិ សត្ថារេភិ |
| ច. | សត្ថុ សត្ថុនោ សត្ថុស្ស | សត្ថារានំ សត្ថានំ |
| មី. | សត្ថារា | សត្ថារេហិ សត្ថារេភិ |
| ឆ. | សត្ថុ សត្ថុនោ សត្ថុស្ស | សត្ថារានំ សត្ថានំ |
| ស. | សត្ថរិ | សត្ថារេសុ |

**កត្តុ** [ អ្នកធ្វើ ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | កត្តា | កត្តារោ |
| អា. | កត្ត កត្តា | កត្តារោ |
| ទុ. | កត្តារំ | កត្តារេ កត្តារោ |
| ត. | កត្តារា | កត្តារេហិ កត្តារេភិ |
| ច. | កត្តុ កត្តុនោ កត្តុស្ស | កត្តារានំ កត្តានំ កត្តូនំ កត្តុនំ |
| មី. | កត្តារា | កត្តារេហិ កត្តារេភិ |
| ឆ. | កត្តុ កត្តុនោ កត្តុស្ស | កត្តារានំ កត្តានំ កត្តូនំ កត្តុនំ |
| ស. | កត្តរិ | កត្តារេសុ កត្តូសុ កត្តុសុ |

## សព្ទបំបែកដូច កត្តុ

ភត្តុ វត្តុ នេតុ សោតុ ញាតុ ជេតុ ឆេត្តុ ភេត្តុ

ទាតុ ធាតុ នត្តុ ពោទ្ធុ វិញ្ញាបេតុ អាទយោបិ. (បទរូបសិទ្ធិ)

* * * * * * *

**ភត្តុ** = អ្នកចិញ្ចឹម ភស្តា, **វត្តុ** = អ្នកនិយាយ, **នេតុ** = អ្នកនាំទៅ, **សោតុ** = អ្នកស្តាប់ អ្នករៀន, **ញាតុ** = អ្នកដឹង, **ជេតុ** = អ្នកឈ្នះ, **ឆេត្តុ** = អ្នកកាប់ឬកាត់, **ភេត្តុ** = អ្នកបំផ្លាញ អ្នកបំបែក, **ទាតុ** = អ្នកឲ្យ, **ធាតុ** = អ្នកទ្រទ្រង់ អ្នកបង្កើត, **នត្តុ** = ចៅ, **ពោទ្ធុ** = អ្នកយល់ដឹង, **វិញ្ញាបេតុ** = អ្នកឲ្យដឹង អ្នកឲ្យដំណឹង

* * * * * * *

សត្ថុ កត្តុ ភត្តុ វត្តុ　　សោតុ ញាតុ ជេតុ ឆេត្តុ
ភេត្តុ នត្តុ ទាតុ ធាតុ　　វិញ្ញាបេតុ ពោទ្ធុ ភោត្តុ ។ (កច្ចាយនសុត្តត្ថៈ)

<u>កង្កែបក្នុងអណ្តូង</u>

**អប្បស្សុតោ សុតំ អប្បំ　　ពហុំ មញ្ញតិ មានវា**
**សិន្ធុទកំ អបស្សន្តោ　　កូបេ តោយំវ មណ្ឌុកោ.**

ខ្លៅប្រៀនរៀនត្រាប់ស្តាប់តិចតួច　　សម្គាល់ខ្លួនស្រួចមិនចេះទាល់
មិនដឹងពុទ្ធពេចន៍នៅសេសសល់　　ដូចកល់កង្កែបបែបកម្លៅ ។
នៅក្នុងអណ្តូងរណ្តៅទាល់　　មិនដែលទៅស្គាល់សមុទ្រជ្រៅ
សម្គាល់អណ្តូងដែលខ្លួននៅ　　ថាជ្រៅថាធំលើសនានា ។

(លោកនីតិ ១៥)

**សកមន្ទាតុ** [ស្ដេចសកមន្ទាតុ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សកមន្ទាតា | សកមន្ទាតារោ |
| អា. | សកមន្ទាត សកមន្ទាតា | សកមន្ទាតារោ |
| ទុ. | សកមន្ទាតារំ | សកមន្ទាតារេ-រោ |
| ត. | សកមន្ទាតារា | សកមន្ទាតារេហិ-សកមន្ទាតារេភិ |
| ច. | សកមន្ទាតុ | សកមន្ទាតារានំ សកមន្ទាតានំ-តូនំ-តុនំ |
| មី. | សកមន្ទាតារា | សកមន្ទាតារេហិ-សកមន្ទាតារេភិ |
| ឆ. | សកមន្ទាតុ | សកមន្ទាតារានំ សកមន្ទាតានំ-តូនំ-តុនំ |
| ស. | សកមន្ទាតរិ | សកមន្ទាតារេសុ  សកមន្ទាតូសុ-តុសុ |

**បិតុ** [ បិតា ] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | បិតា | បិតរោ |
| អា. | បិត បិតា | បិតរោ |
| ទុ. | បិតរំ | បិតរេ បិតរោ |
| ត. | បិតរា បិតុនា | បិតរេហិ-ភិ បិតូហិ-ភិ បិតុហិ-ភិ |
| ច. | បិតុ បិតុនោ បិតុស្ស | បិតរានំ បិតានំ បិតូនំ បិតុនំ |
| មី. | បិតរា | បិតរេហិ-ភិ បិតូហិ-ភិ បិតុហិ-ភិ |
| ឆ. | បិតុ បិតុនោ បិតុស្ស | បិតរានំ បិតានំ បិតូនំ បិតុនំ |
| ស. | បិតរិ | បិតរេសុ បិតូសុ បិតុសុ |

**មហាមន្ទាតុ** បំបែកដូច សកមន្ទាតុ, សព្វ **ភាតុ** បងប្អូនប្រុស បំបែក ដូច បិតុ ។

**អភិភូ** [ព្រះជាម្ចាស់] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អភិភូ | អភិភូ អភិភុវោ |
| អា. | អភិភុ | អភិភូ  អភិភុវោ |
| ទុ. | អភិភុំ | អភិភូ អភិភុវោ |
| ត. | អភិភុនា | អភិភូហិ អភិភូភិ |
| ច. | អភិភុនោ អភិភុស្ស | អភិភូនំ |
| មី. | អភិភុនា អភិភុស្មា អភិភុម្ហា | អភិភូហិ អភិភូភិ |
| ឆ. | អភិភុនោ អភិភុស្ស | អភិភូនំ |
| ស. | អភិភុស្មឹ អភិភុម្ហិ | អភិភូសុ |

**សយម្ភូ, វេស្សភូ** និង **បរាភិភូ** បំបែកដូច **អភិភូ** ។

**សហភូ** [ អ្នកកើតព្រមគ្នា] ឧការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សហភូ | សហភូ សហភុវោ សហភុនោ |
| អា. | សហភុ | សហភូ សហភុវោ សហភុនោ |
| ទុ. | សហភុំ | សហភូ សហភុវោ សហភុនោ |
| ត. | សហភុនា | សហភូហិ សហភូភិ |
| ច. | សហភុនោ សហភុស្ស | សហភូនំ |
| មី. | សហភុនា សហភុស្មា សហភុម្ហា | សហភូហិ សហភូភិ |
| ឆ. | សហភុនោ សហភុស្ស | សហភូនំ |
| ស. | សហភុស្មឹ សហភុម្ហិ | សហភូសុ |

**សព្វញ្ញូ** [ ព្រះសព្វញ្ញូ ] ឩការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សព្វញ្ញូ | សព្វញ្ញូ សព្វញ្ញុនោ |
| អា. | សព្វញ្ញុ | សព្វញ្ញូ សព្វញ្ញុនោ |
| ទុ. | សព្វញ្ញុំ | សព្វញ្ញូ សព្វញ្ញុនោ |
| ត. | សព្វញ្ញុនា | សព្វញ្ញូហិ សព្វញ្ញូភិ |
| ច. | សព្វញ្ញុនោ សព្វញ្ញុស្ស | សព្វញ្ញូនំ |
| មី. | សព្វញ្ញុនា សព្វញ្ញុស្មា សព្វញ្ញុម្ហា | សព្វញ្ញូហិ សព្វញ្ញូភិ |
| ឆ. | សព្វញ្ញុនោ សព្វញ្ញុស្ស | សព្វញ្ញូនំ |
| ស. | សព្វញ្ញុស្មឹ សព្វញ្ញុម្ហិ | សព្វញ្ញូសុ |

មគ្គញ្ញូ,ធម្មញ្ញូ,អត្ថញ្ញូ,កាលញ្ញូ,រត្តញ្ញូ,មត្តញ្ញូ, កតញ្ញូ, តថញ្ញូ, វិញ្ញូ, វិទូ, វេទគូ, បារគូ បំបែកដូច សព្វញ្ញូ

**គោ** [ គោ ]  ឱការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គោ | គាវោ គវោ |
| អា. | គោ | គាវោ គវោ |
| ទុ. | គាវុំ គាវំ គវំ | គាវោ គវោ |
| ត. | គាវេន គវេន | គោហិ គោភិ |
| ច. | គាវស្ស គវស្ស | គវំ គុន្នំ គោនំ |
| មី. | គាវា គាវស្មា គាវម្ហា គវា គវស្មា គវម្ហា | គោហិ គោភិ |
| ឆ. | គាវស្ស គវស្ស | គវំ គុន្នំ គោនំ |
| ស. | គាវេ គាវស្មឹ គាវម្ហិ គវេ គវស្មឹ គវម្ហិ | គាវេសុ គវេសុ គោសុ |

## សង្គហគាថា

បុរិសោ គុណវា រាជា　　　សាគ្គិ ទណ្ឌី ច ភិក្ខុ ច

សត្ថាភិភូ ច សព្ពញ្ញូ　　　គោតិ បុល្លិង្គសង្គហោ.

## សរុបការន្តបុល្លិង្គ

| | | | |
|---|---|---|---|
| បុរិស | អការន្ត បុំ. | អាប អការន្ត បុំ. | ថាម អការន្ត បុំ. |
| គុណវន្តុ | ឧការន្ត បុំ. | ហិមវន្តុ ឧការន្ត បុំ. | សតិមន្តុ ឧការន្ត បុំ. |
| គច្ឆន្ត | អការន្ត បុំ. | ភវន្ត អការន្ត បុំ. | ភទន្ត អការន្ត បុំ. |
| សន្ត | អការន្ត បុំ. | រាជ អការន្ត បុំ. | ព្រហ្ម អការន្ត បុំ. |
| អត្ត | អការន្ត បុំ. | សខ អការន្ត បុំ. | អាតុម អការន្ត បុំ. |
| បុម | អការន្ត បុំ. | យុវ អការន្ត បុំ. | សា អាការន្ត បុំ. |
| អគ្គិ | ឥការន្ត បុំ. | ទណ្ឌី ឦការន្ត បុំ. | ភិក្ខុ ឧការន្ត បុំ. |
| ហេតុ | ឧការន្ត បុំ. | ជន្តុ ឧការន្ត បុំ. | សត្ថុ ឧការន្ត បុំ. |
| កត្តុ | ឧការន្ត បុំ. | សកមន្ធាតុ ឧការន្ត បុំ. | បិតុ ឧការន្ត បុំ. |
| អភិភូ | ឩការន្ត បុំ. | សហាភូ ឩការន្ត បុំ. | សព្ពញ្ញូ ឩការន្ត បុំ. |
| គោ | ឱការន្ត បុំ. | | |

**នត្ថិ វិជ្ជាសមំ មិត្តំ　　　នត្ថិ ព្យាធិសមោ រិបុ**

**នត្ថិ អត្តសមំ បេមំ　　　នត្ថិ កម្មសមំ ពលំ.**

មានទ្រព្យមិនស្មើមានវិជ្ជា　　　មានរោគាមិនស្មើពាលគង្វាន

ស្រឡាញ់អ្វីមិនស្មើស្រឡាញ់ប្រាណ　　　កម្លាំងអ្វីមិនស្មើស្មានកម្លាំងកម្ម ។

(លោកនីតិ ២៣)

## ២. ឥត្ថិលិង្គ

**កញ្ញា** [ កញ្ញា ] អាការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | កញ្ញា | កញ្ញា កញ្ញាយោ |
| អា. | កញ្ញេ | កញ្ញា កញ្ញាយោ |
| ទុ. | កញ្ញំ | កញ្ញា កញ្ញាយោ |
| ត. | កញ្ញាយ | កញ្ញាហិ កញ្ញាភិ |
| ច. | កញ្ញាយ | កញ្ញានំ |
| មី. | កញ្ញាយ | កញ្ញាហិ កញ្ញាភិ |
| ឆ. | កញ្ញាយ | កញ្ញានំ |
| ស. | កញ្ញាយំ កញ្ញាយ | កញ្ញាសុ |

**អម្មា** [ ម៉ាក់ ] អាការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អម្មា | អម្មា អម្មាយោ |
| អា. | អម្ម អម្មា | អម្មា អម្មាយោ |
| ទុ. | អម្មំ | អម្មា អម្មាយោ |
| ត. | អម្មាយ | អម្មាហិ អម្មាភិ |
| ច. | អម្មាយ | អម្មានំ |
| មី. | អម្មាយ | អម្មាហិ អម្មាភិ |
| ឆ. | អម្មាយ | អម្មានំ |
| ស. | អម្មាយំ អម្មាយ | អម្មាសុ |

**អន្នា** និង **អម្ពា** បំបែកដូច **អម្មា**

## សព្ទបំបែកដូច កញ្ញា

សទ្ធា មេធា បញ្ញា វិជ្ជា ចិន្តា មន្តា វីណា តណ្ហា
ឥច្ឆា មុច្ឆា ឯជា មាយា មេត្តា មត្តា សិក្ខា ភិក្ខា.
ជង្ឃា គីវា ជិវ្ហា វាចា ឆាយា អាសា គង្គា នាវា
គាថា សេនា លេខា សាលា មាលា វេលា បូជា ខិឌ្ឌា.
បិបាសា វេទនា សញ្ញា ចេតនា តសិនា បជា
ទេវតា វដ្តកា គោធា ពលាកា បរិសា សភា.
ឧកា សេផាលិកា លង្កា សលាកា វាលិកា សិខា
វិសាខា វិសិខា សាខា វចា វញ្ឈា ជដា ឃដា.
ជេដ្ឋា សោណ្ឌា វិតណ្ឌា ច ករុណា វនិតា លតា
កថា និទ្ទា សុធា រាធា វាសនា សីសបា បបា.
បភា សីមា ខមា ជាយា ខត្តិយា សក្ខរា សុរា
ទោលា តុលា សិលា លីលា លាលេលា មេខលា កលា.
វឡវាលម្ពុសា មូសា មញ្ជូសា សុលសា ទិសា
នាសា ជុណ្ហា គុហា ឦហា លសិកា វសុធាទយោ.

**<u>លោកវៀនមិនច្បាស់ត្រង់ណា</u>**

**យោ សិស្សោ សិប្បលោភេន ពហុំ គណ្ហាតិ តំ សិប្បំ**
**មូគោវ សុបិនំ បស្សំ កថេតុម្បិ ន ឧស្សហេ.**

សិស្សឯនាលោភរបៀនរៀនរួសបទ ចាំមិនស្ទាត់មាត់មិនស្ដែងថ្លែងមិនបាន
ដូចមនុស្សគយល់សប្តិដឹងសព្វស្ថាន ថ្លែងពុំបានរំខានចិត្តអ៊ិះអ៊ុះអើយ ។

(លោកនីតិ ៣៨)

## សព្ទបំបែកដូច កញ្ញា

**សទ្ធា** = សទ្ធា ជំនឿ, **មេធា** = ប្រាជ្ញា, **បញ្ញា** = បញ្ញា ប្រាជ្ញា, **វិជ្ជា** = ចំណេះវិទ្យា, **ចិន្តា** = គំនិត, **មន្តា** = ប្រាជ្ញា, **វីណា** = ពិណ ចាប៉ី, **តណ្ហា** = តណ្ហា, **ឥច្ឆា** = សេចក្តីប្រាថ្នា, **មុច្ឆា** = ការបាត់ស្មារតី, សន្លប់, **ឯជា** =សេចក្តីត្រូវការ, **មាយា** = ពុតត្បុត, **មេត្តា** = មេត្តា, **មត្តា** = ប្រមាណ, **សិក្ខា** = ចំណុចដែលគួរសិក្សា, **ភិក្ខា** = ចង្ហាន់, **ជង្ឃា** = ស្មង, **គីវា** = ក, **ជិវ្ហា** = អណ្តាត, **វាចា** = វាចា, **ឆាយា** = ម្លប់ស្រមោល **អាសា** = សេចក្តីសង្ឃឹម, **គង្គា** = ទន្លេគង្គា, **នាវា** = ទូក សំពៅ កប៉ាល់, **គាថា** = គាថា, **សេនា** = កងទ័ព, **លេខា** = គំនូស ចំណារ, **សាលា** = រោង, **មាលា** = កម្រងផ្កា, **វេលា** = ត្រើយពេល ពេលវេលា, **បូជា** = ការបូជា, **ខិឌ្ឌា** = ការលេង ល្បែង កីឡា, **បិបាសា** = សេចក្តីស្រេក, **វេទនា** = សំណោយ, **សញ្ញា** = ឈ្មោះ, **ចេតនា** = ចេតនា, **តសិនា** = ចំណង់, **បជា** = ពួកសត្វ ប្រជាជន, **ទេវតា** = ទេព្តា, **វដ្តកា** = សត្វក្រួច, **គោធា** = ទន្សង, **ពលាកា** = កុក, **បរិសា** =បរិស័ទ, **សភា** = ទីប្រជុំ សភា, **ឱភា** = ចៃ, **សេផាលិកា** = សារាយ កន្ទួតព្រៃ **លង្កា** = កោះលង្កា, **សលាកា** = ស្លាកខ្នាច់ ឆ្នោត, **វាលិកា** = ខ្សាច់, **សិខា** = អណ្តាតភ្លើង, **វិសាខា** = ផ្កាយវិសាខា, **វិសិខា** = ថ្នល់, **សាខា** = មែក, **វចា** = ប្រទាល, **វញ្ឈា** = ស្រីអារ, **ជដា** = កណ្តាញ់សក់ ផ្នួងសក់, **ឃដា** = ពួក បន ក្រុមហ្វូង, **ជេដ្ឋា** = ផ្កាយជេដ្ឋា, **សោណ្ឌា** = ប្រមោយដំរី, **វិតណ្ឌា** = ពាក្យមិច្ឆាទិដ្ឋិ, **ករុណា** = សេចក្តីអាណិត, **វនិតា** = ស្រីក្រមុំ, **លតា** = វល្លិ៍, **កថា** = រឿង, **និទ្ទា** = ដំណេក, **សុធា** = កំបោរស, **រាធា** = ផ្កាយក្ងោក, **វាសនា** = សំណាង, **សឹសបា** = ដើមធ្នង់, **បបា** = រោងទឹកផឹក, **បភា** = ពន្លឺ, **សីមា** = សីមា, **ខមា** = អំណត់, **ជាយា** = ប្រពន្ធ, **ខត្តិយា** = ក្សត្រី, **សក្ខរា** = ដុំក្រួស, **សុរា** = ស្រា, **ទោលា** = ទោង អង្រឹង, **តុលា** = ជញ្ជីង, **សិលា** = ថ្ម, **លីលា** = ដំណើរយាងយាស, **លាលា** = ទឹកមាត់, **ឯលា** = ទឹកមាត់, **មេខលា** = ខ្សែក្រវាត់, **កលា** = បំណែក, **វគ្គុលា** = សត្វលា, **អលម្ពុសា** = ឈ្មោះទេពកញ្ញា, **មូសា** = មេពុម្ព, **មញ្ជូសា** = ហឹប, **សុលសា** = នាងសុលសា, **ទិសា** = ទិស, **នាសា** = ច្រមុះ, **ជុណ្ហា** = ខែភ្លឺ ខ្មៃត, **គុហា** = ល្អាង រូងភ្នំ, **ឦហា** = សេចក្តីព្យាយាម, **លសិកា** = សំបោរ, **វសុធា** = ផែនដី ។

* * * * * * * *

**រត្តិ** [ រាត្រី ] ឥការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | រត្តិ | រត្តី រត្តិយោ រត្យោ |
| អា. | រត្តិ | រត្តី រត្តិយោ |
| ទុ. | រត្តឹ | រត្តី រត្តិយោ |
| ត. | រត្តិយា | រត្តីហិ-រត្តីភិ រត្តិហិ-រត្តិភិ |
| ច. | រត្តិយា | រត្តីនំ រត្តិនំ |
| មី. | រត្តិយា រត្យា | រត្តីហិ-រត្តីភិ រត្តិហិ-រត្តិភិ |
| ឆ. | រត្តិយា | រត្តីនំ រត្តិនំ |
| ស. | រត្យំ រត្តិយំ រត្យា រត្តឹ រត្តោ រត្តិយា | រត្តីសុ រត្តិសុ |

**បត្តិ** [ ចំណែកបុណ្យ ] ឥការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | បត្តិ | បត្តី បត្តិយោ |
| អា. | បត្តិ | បត្តី បត្តិយោ |
| ទុ. | បត្តឹ | បត្តី បត្តិយោ |
| ត. | បត្តិយា | បត្តីហិ-បត្តីភិ បត្តិហិ-បត្តិភិ |
| ច. | បត្តិយា | បត្តីនំ បត្តិនំ |
| មី. | បត្តិយា | បត្តីហិ-បត្តីភិ បត្តិហិ-បត្តិភិ |
| ឆ. | បត្តិយា | បត្តីនំ បត្តិនំ |
| ស. | បត្តិយំ បត្តិយា | បត្តីសុ បត្តិសុ |

## **សព្ទបំបែកដូច រត្តិ**

បត្តិ យុត្តិ វុត្តិ កិត្តិ មុត្តិ តិត្តិ ខន្តិ កន្តិ

សន្តិ តន្តិ សិទ្ធិ សុទ្ធិ ឥទ្ធិ វុទ្ធិ ពុទ្ធិ ពោធិ.

ភូមិ ជាតិ បីតិ សូតិ នន្ទិ សន្ធិ សាណិ កោដិ

ទិដ្ឋិ វុឌ្ឍិ តុដ្ឋិ យដ្ឋិ បាឡិ អាឡិ នាឡិ កេឡិ.

សតិ មតិ គតិ ចុតិ, ធិតិ យុវតិ វិកតិ, រតិ រុចិ រស្មិ អសនិ, វសនិ ឱសធិ អង្គុលិ ធូលិ, ទុន្ទុភិ ទោណិ អដវិ ឆវិ អាទីនិ ឥការន្តនាមានិ.

( វៀរលែងរូប រត្យោ ក្នុង បឋមា, រត្យា ក្នុង បញ្ចមី និង រត្យា រត្យំ រត្តឹ រត្តោ ក្នុង សត្តមី ក្រៅពីនេះ បំបែក ដូច រត្តិ )

* * * * * * * *

**បត្តិ** = ទាហានជើងគោក, **យុត្តិ** = សេចក្តីសមគួរ, **វុត្តិ** = ពាក្យអធិប្បាយសូត្រ, **កិត្តិ** = កិត្តិនាម, **មុត្តិ** = សេចក្តីរួចផុត, **តិត្តិ** = សេចក្តីឆ្អែត, **ខន្តិ** = អំណត់, **កន្តិ** = សម្រស់,**សន្តិ** = សេចក្តីស្ងប់, **តន្តិ** = បែបផែន, **សិទ្ធិ** = សេចក្តីសម្រេច, **សុទ្ធិ** = សេចក្តីបរិសុទ្ធ, **ឥទ្ធិ** =ឫទ្ធិ៍, **វុទ្ធិ** = សេចក្តីចម្រើន, **ពុទ្ធិ** = ប្រាជ្ញា, **ពោធិ** = ការត្រាស់ដឹង,**ភូមិ** = ផែនដី, **ជាតិ** = ការកើត,ប្រភេទ, **បីតិ** =សេចក្តីឆ្អែតចិត្ត, **សូតិ** = ការកើត, **នន្ទិ** = សេចក្តីភ្លើតភ្លើន, **សន្ធិ** = បដិសន្ធិ, **សាណិ** = វាំងនន, **កោដិ** = ចុង កោដិ, **ទិដ្ឋិ** = គំហើញ សេចក្តីយល់ឃើញ, **វុឌ្ឍិ** = សេចក្តីចម្រើន, **តុដ្ឋិ** = អំណរ, **យដ្ឋិ** = ឈើច្រត់, **បាឡិ** = ជួរ រឹម បាឡី, **អាឡិ** = ជួរ, **នាឡិ** = នាល, **កេឡិ** = ការលេង, **សតិ** = សេចក្តីរលឹក, **មតិ** = សេចក្តីយល់ដឹង, **គតិ** = ទំនៅ ការទៅ, **ចុតិ** = ការឃ្លាត ការច្យុត, **ធិតិ** = សេចក្តីប្រឹងប្រែង, **យុវតិ** = ស្រីជំទង់, **វិកតិ** = ការផ្លាស់ប្តូរ, **រតិ** = សេចក្តីត្រេកអរ, **រុចិ** = សេចក្តីគាប់ចិត្ត, **រស្មិ** = រស្មី, **អសនិ** = ផ្លេកបន្ទោរ, **វសនិ** = ក្រណាត់ សំពត់ **ឱសធិ** = ផ្កាយព្រឹក, **អង្គុលិ** = ម្រាមដៃ, **ធូលិ** = កំទេច ល្អង ធូលី, **ទុន្ទុភិ** = ស្គរធំ, **ទោណិ** = ស្នូកឈើ, **អដវិ** = ដងព្រៃ, **ឆវិ** = សម្បុរស្បែក ។

**ឥត្ថី** [ ស្រី ] ឦការន្ត ឥ. បំបែក ដូច្នេះស

| | ឯក. | ពហុ. |
|---|---|---|
| ប. | ឥត្ថី | ឥត្ថី ឥត្ថិយោ |
| អា. | ឥត្ថិ | ឥត្ថី ឥត្ថិយោ |
| ទុ. | ឥត្ថិយំ ឥត្ថឹ | ឥត្ថី ឥត្ថិយោ |
| ត. | ឥត្ថិយា | ឥត្ថីហិ ឥត្ថីភិ |
| ច. | ឥត្ថិយា | ឥត្ថីនំ |
| មី. | ឥត្ថិយា | ឥត្ថីហិ ឥត្ថីភិ |
| ឆ. | ឥត្ថិយា | ឥត្ថីនំ |
| ស. | ឥត្ថិយំ  ឥត្ថិយា | ឥត្ថីសុ |

**នទី** [ ស្ទឹង ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | នទី | នទី នជ្ជោ នទិយោ |
| អា. | នទិ | នទី នជ្ជោ នទិយោ |
| ទុ. | នទិយំ នទឹ | នទី នជ្ជោ នទិយោ |
| ត. | នជ្ជា នទិយា | នទីហិ នទីភិ |
| ច. | នជ្ជា នទិយា | នទីនំ |
| មី. | នជ្ជា នទិយា | នទីហិ នទីភិ |
| ឆ. | នជ្ជា នទិយា | នទីនំ |
| ស. | នជ្ជំ នទិយំ នទិយា | នទីសុ |

## សព្ទបំបែក ឥត្ថី

មហី វេតរណី វាបី បាដលី កទលី យដី
នារី កុមារី តរុណី វារុណី ព្រាហ្មណី សខី.
គន្ធព្វី កិន្នរី នាគី ទេវី យក្ខី អជី មិគី
វានរី សូករី សីហី ហំសី កាកី ច កុក្កុដី.

មានវី, នាវិកី, វេនតេយ្យី, គោតមី, គុណវតី, កុលវតី, សីលវតី, យសវតី, រូបវតី, សតិមតី, គោមតី, មហាតី, ភោតី, ភិក្ខុនី, គហបតានី, រាជិនី, ទណ្ឌិនី, ហត្ថិនី, មេធាវិនី, តបស្សិនី, បិយភាណិនី, ភយទស្សាវិនី, ភុត្តាវិនី, ធម្មចារិនី, បរចិត្តវិទុនី, យក្ខិនី, សីហិនី, មាតុលានី, អយ្យកានី, វរុណានី ។

* * * * * * * *

**មហី** = ផែនដិ, **វេតរណី** = ស្ទឹងវេតរណី, **វាបី** = បឹង, **បាដលី** = ដើមច្រនៀង, **កទលី** = ដើមចេក, **យដី** = ក្អមទឹក, **នារី** = ស្រី, **កុមារី** = ក្មេងស្រី, **តរុណី** = ក្រមុំ, **វារុណី** = ធ្មប់, **ព្រាហ្មណី** = ព្រាហ្មណី, **សខី** = ម្រាក់ (មិត្តស្រី សម្លាញ់ស្រី), **គន្ធព្វី** = នាងគន្ធព្វ, **កិន្នរី** = នាងកិន្នរ, **នាគី** = នាងនាគ, **ទេវី** = ព្រះរាជិនី, **យក្ខី** = នាងយក្ស, **អជី** = ពពែញី, **មិគី** = ក្ដាន់ញី, **វានរី** = ស្វាញី, **សូករី** = ជ្រូកញី, **សីហី** = តោញី, **ហំសី** = ហង្សញី, **កាកី** = ក្អែកញី, **កុក្កុដី** = មាន់ញី ។

<u>នៅក្បែរបណ្ឌិតមិនស្វែងវិជ្ជា</u>

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ**
**ន សោ ធម្មំ វិជានាតិ ទព្វិ សូបរសំ យថា.**

ពាលខ្លៅចូលទៅផងបណ្ឌិត គ្រាអស់ជីវិតលង់អនេក
មិនដឹងរសធម៌អាថ៌ជាឯក ដូចវែកមិនដឹងរសសម្ល ។

(លោកនីតិ ២៥)

**បុថវី** [ ផែនដី ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | បុថវី | បុថវី បុថវិយោ |
| អា. | បុថវិ | បុថវី បុថវិយោ |
| ទុ. | បុថវិយំ បុថវឹ | បុថវី បុថវិយោ |
| ត. | បុថវិយា | បុថវីហិ បុថវីភិ |
| ច. | បុថព្យា បុថវិយា | បុថវីនំ |
| មី. | បុថព្យា បុថវិយា | បុថវីហិ បុថវីភិ |
| ឆ. | បុថព្យា បុថវិយា | បុថវីនំ |
| ស. | បុថព្យំ បុថវិយំ បុថវិយា | បុថវីសុ |

[ **បថវី បឋវី បឍវី បុថវី** មានន័យដូចគ្នា គឺ ផែនដី ]

**គាវី** [ គោញី] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គាវី | គាវី គាវិយោ |
| អា. | គាវិ | គាវី គាវិយោ |
| ទុ. | គាវិយំ គាវឹ | គាវី គាវិយោ |
| ត. | គាវិយា | គាវីហិ គាវីភិ |
| ច. | គាវិយា | គាវីនំ |
| មី. | គាវិយា | គាវីហិ គាវីភិ |
| ឆ. | គាវិយា | គាវីនំ |
| ស. | គាវិយំ គាវិយា | គាវីសុ |

**គុណវតី** [ ស្ត្រីដែលមានគុណ ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គុណវតី | គុណវតី គុណវតិយោ |
| អា. | គុណវតិ | គុណវតី គុណវតិយោ |
| ទុ. | គុណវតិយំ គុណវតឹ | គុណវតី គុណវតិយោ |
| ត. | គុណវតិយា | គុណវតីហិ គុណវតីភិ |
| ច. | គុណវតិយា | គុណវតីនំ |
| មី. | គុណវតិយា | គុណវតីហិ គុណវតីភិ |
| ឆ. | គុណវតិយា | គុណវតីនំ |
| ស. | គុណវតិយំ គុណវតិយា | គុណវតីសុ |

**គុណវន្តី** [ ស្ត្រីដែលមានគុណ ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គុណវន្តី | គុណវន្តី គុណវន្តិយោ |
| អា. | គុណវន្តិ | គុណវន្តី គុណវន្តិយោ |
| ទុ. | គុណវន្តិយំ គុណវន្តឹ | គុណវន្តី គុណវន្តិយោ |
| ត. | គុណវន្តិយា | គុណវន្តីហិ គុណវន្តីភិ |
| ច. | គុណវន្តិយា | គុណវន្តីនំ |
| មី. | គុណវន្តិយា | គុណវន្តីហិ គុណវន្តីភិ |
| ឆ. | គុណវន្តិយា | គុណវន្តីនំ |
| ស. | គុណវន្តិយំ គុណវន្តិយា | គុណវន្តីសុ |

## សព្ទបំបែកដូច គុណវតី

**មានវី** = មនុស្សស្រី, **នាវិកី** = ស្រីដែលឆ្លងដោយទូក, **វេនតេយ្យី** = ធីតានាងវិន្តា, **គោតមី** = ធីតានាងគោតមី, **គុណវតី** = ស្រីដែលមានគុណ, **កុលវតី** = ស្រីដែលមានត្រកូល, **សីលវតី** = ស្រីដែលមានសីល, **យសវតី** = ស្រីដែលមានយស, **រូបវតី** = ស្រីដែលមានរូបសម្រស់, **សតិមតី** = ស្រីដែលមានស្មារតីល្អ, **គោមតី** = ស្រីដែលមានគោច្រើន, **មហតី** = ស្រីដែលបូជា ធំ, **ភោតី** = នាងដ៏ចម្រើន, **ភិក្ខុនី**= ភិក្ខុនី, **គហបតានី** = ស្រីម្ចាស់ផ្ទះ, **ភិក្ខុនី** = ភិក្ខុនី, **រាជិនី** = ស្តេចស្រី, **ទណ្ឌិនី** = ស្រីដែលមានឈើច្រត់, **ហត្ថិនី** = ដំរីញី, **មេធាវិនី** = ស្រីដែលមានប្រាជ្ញា, **តបស្សិនី** = ស្រីដែលមានតបៈ, **បិយភាណិនី** = ស្រីដែលនិយាយសំដីពីរោះ, **ភយទស្សាវិនី** = ស្រីដែលឃើញគ្រោះភ័យ, **ភុត្តាវិនី** = ស្រីដែលបរិភោគ, **ធម្មចារិនី** = ស្រីដែលប្រព្រឹត្តធម៌, **បរចិត្តវិទុនី** = ស្រីដែលដឹងចិត្តអ្នកដទៃ, **យក្ខិនី** = ស្រីយក្ស, **សីហិនី** = តោញី, **មាតុលានី** = មីង, **អយ្យកានី** = យាយ, **វរុណានី** = ជាយារបស់ព្រះវរុណ ។

* * * * * * * *

**គច្ឆន្តី** [ កំពុងទៅ ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គច្ឆន្តី | គច្ឆន្តី គច្ឆន្តិយោ |
| អា. | គច្ឆន្តិ | គច្ឆន្តី គច្ឆន្តិយោ |
| ទុ. | គច្ឆន្តិយំ គច្ឆន្តឹ | គច្ឆន្តី គច្ឆន្តិយោ |
| ត. | គច្ឆន្តិយា | គច្ឆន្តីហិ គច្ឆន្តីភិ |
| ច. | គច្ឆន្តិយា | គច្ឆន្តីនំ |
| មី. | គច្ឆន្តិយា | គច្ឆន្តីហិ គច្ឆន្តីភិ |
| ឆ. | គច្ឆន្តិយា | គច្ឆន្តីនំ |
| ស. | គច្ឆន្តិយា គច្ឆន្តិយំ | គច្ឆន្តីសុ |

**ករោន្តី** [ កំពុងធ្វើ ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ករោន្តី | ករោន្តី  ករោន្តិយោ |
| អា. | ករោន្តិ | ករោន្តី ករោន្តិយោ |
| ទុ. | ករោន្តិយំ ករោន្តឹ | ករោន្តី ករោន្តិយោ |
| ត. | ករោន្តិយា | ករោន្តីហិ ករោន្តីភិ |
| ច. | ករោន្តិយា | ករោន្តីនំ |
| មី. | ករោន្តិយា | ករោន្តីហិ ករោន្តីភិ |
| ឆ. | ករោន្តិយា | ករោន្តីនំ |
| ស. | ករោន្តិយា  ករោន្តិយំ | ករោន្តីសុ |

**បោក្ខរណី** [ ស្រះឈូក ] ឦការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | បោក្ខរណី | បោក្ខរណី បោក្ខរញ្ញោ បោក្ខរណិយោ |
| អា. | បោក្ខរណិ | បោក្ខរណី បោក្ខរញ្ញោ បោក្ខរណិយោ |
| ទុ. | បោក្ខរណិយំ បោក្ខរណឹ | បោក្ខរណី បោក្ខរញ្ញោ បោក្ខរណិយោ |
| ត. | បោក្ខរញ្ញា បោក្ខរណិយា | បោក្ខរណីហិ បោក្ខរណីភិ |
| ច. | បោក្ខរញ្ញា បោក្ខរណិយា | បោក្ខរណីនំ |
| មី. | បោក្ខរញ្ញា បោក្ខរណិយា | បោក្ខរណីហិ បោក្ខរណីភិ |
| ឆ. | បោក្ខរញ្ញា បោក្ខរណិយា | បោក្ខរណីនំ |
| ស. | បោក្ខរញ្ញំ បោក្ខរណិយំ បោក្ខរណិយា | បោក្ខរណីសុ |

**យាគុ** [ បបរ ] ឧការន្ត ឥ. បំបែក ដូច្នេះ

ឯក. ពហុ.

| | | |
|---|---|---|
| ប. | យាគុ | យាគូ យាគុយោ |
| អា. | យាគុ | យាគូ យាគុយោ |
| ទុ. | យាគុំ | យាគូ យាគុយោ |
| ត. | យាគុយា | យាគូហិ-យាគូភិ យាគុហិ-យាគុភិ |
| ច. | យាគុយា | យាគូនំ យាគុនំ |
| មី. | យាគុយា | យាគូហិ-យាគូភិ យាគុហិ-យាគុភិ |
| ឆ. | យាគុយា | យាគូនំ យាគុនំ |
| ស. | យាគុយំ យាគុយា | យាគូសុ យាគុសុ |

## សព្វបំបែក យាគុ

យាគុ ធាតុ កាសុ ធេនុ ទទ្ទុ កណ្ឌុ កណ្ឌុ ច

វជ្ជុ សស្សុ បិយង្គុទ្យូ- ត្យុការន្តិត្ថិកា តថា.

* * * * * * * *

**យាគុ** = បបរ, **ធាតុ** = អ្នកទ្រទ្រង់ អ្នកបង្កើត **កាសុ** = រណ្ដៅ, **ធេនុ** = មេគោទឹកដោះ, **ទទ្ទុ** = ស្រែង, **កណ្ឌុ** = រោគក្លឹ, **ករេណុ** = ដំរីញី, **វជ្ជុ** = ខ្សែ, **សស្សុ** = ម៉ែក្មេក, **បិយង្គុ** = ដើមប្រយង្គុ, **ឧទ្យុ** = ផ្កាយ, **ឧតុ** = រដូវ ។

* * * * * * * *

**មាតុ** [ មាតា ] ឧការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | មាតា | មាតរោ |
| អា. | មាត មាតា | មាតរោ |
| ទុ. | មាតរំ | មាតរេ មាតរោ |
| ត. | មាតរា មាតុយា មត្យា | មាតរេហិ-មាតរេភិ មាតូហិ-មាតូភិ មាតុហិ-មាតុភិ |
| ច. | មាតុ មាតុស្ស មាតុយា | មាតរានំ មាតានំ មាតូនំ មាតុនំ |
| មី. | មាតរា មាតុយា | មាតរេហិ-មាតរេភិ មាតូហិ-មាតូភិ មាតុហិ-មាតុភិ |
| ឆ. | មាតុ មាតុស្ស មាតុយា | មាតរានំ មាតានំ មាតូនំ មាតុនំ |
| ស. | មាតរិ | មាតរេសុ មាតូសុ មាតុសុ |

**ធីតុ** ( កូនស្រី ) និង **ទុហិតុ** ( កូនស្រី ) បំបែកដូច **មាតុ**

**ជម្ពូ** [ ដើមព្រីង ] ឩការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ជម្ពូ | ជម្ពូ ជម្ពុយោ |
| អា. | ជម្ពុ | ជម្ពូ ជម្ពុយោ |
| ទុ. | ជម្ពុំ | ជម្ពូ ជម្ពុយោ |
| ត. | ជម្ពុយា | ជម្ពូហិ ជម្ពូភិ |
| ច. | ជម្ពុយា | ជម្ពូនំ |
| មី. | ជម្ពុយា | ជម្ពូហិ ជម្ពូភិ |
| ឆ. | ជម្ពុយា | ជម្ពូនំ |
| ស. | ជម្ពុយំ ជម្ពុយា | ជម្ពូសុ |

សព្ទបំបែក **ជម្ពូ**

| | |
|---|---|
| វធូ ជម្ពូ ចមូ កច្ឆូ | សរភូ សរពូ សុភូ |
| វាម្មូ នាគនាសូ្ហ | សុតនូការអន្តកា. |

* * * * * * *

**វធូ** = កូនក្រមុំ,កូនប្រសាស្រី, **ជម្ពូ** = ព្រីង, **ចមូ**=កងទ័ព, **កច្ឆូ** = កមរមាស់, **សរភូ** = ស្ទឹងសរភូ,**សរពូ** = តុកកែ,ជីងចក់, **សុភ្ជូ** = ស្រីមានចិញ្ចើមស្អាត, **វាម្មូ** = ស្រីមានភ្លៅស្អាត, **នាគនាសូ្ហ** = ស្រីមានភ្លៅស្អាតដូចប្រមោយដំរី, **សុតនូ** =ស្រីមានរាងស្អាត ។

* * * * * * *

**គោ** [ គោញ្ញី ] ឱការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គោ | គាវោ គវោ |
| អា. | គោ | គាវោ គវោ |
| ទុ. | គាវុំ គាវំ គវំ | គាវោ គវោ |
| ត. | គាវេន គវេន | គោហិ គោភិ |
| ច. | គាវស្ស គវស្ស | គវំ គុន្នំ គោនំ |
| បំ. | គាវា គាវស្មា គាវម្ហា គវា គវស្មា គវម្ហា | គោហិ គោភិ |
| ឆ. | គាវស្ស គវស្ស | គវំ គុន្នំ គោនំ |
| ស. | គាវេ គាវស្មឹ គាវម្හិ គវេ គវស្មឹ គវម្ហិ | គាវេសុ គវេសុ គោសុ |

## សង្គហគាថា

កញ្ញា រត្តិ នទី ឥត្ថី មាតុលានី ច ភិក្ខុនី
ទណ្ឌិនី យាគុ មាតា ច ជម្ពូ គោតិត្ថិសង្គហោ.

## សរុបការន្តឥត្ថិលិង្គ

**កញ្ញា** អារន្ត ឥ., **អម្មា** អាការន្ត ឥ., **រត្តិ** ឥការន្ត ឥ., **បត្តិ** ឥការន្ត ឥ., **ឥត្ថី** ឦការន្ត ឥ., **មាតុលានី** ឦការន្ត ឥ., **ភិក្ខុនី** ឦការន្ត ឥ., **នទី** ឦការន្ត ឥ., **បុថវី** ឦការន្ត ឥ., **គាវី** ឦការន្ត ឥ., **គុណវតី** ឦការន្ត ឥ., **គុណវន្តី** ឦការន្ត ឥ., **គច្ឆន្តី** ឦការន្ត ឥ., **ករោន្តី** ឦការន្ត ឥ., **បោក្ខរណី** ឦការន្ត ឥ., **យាគុ** ឧការន្ត ឥ., **មាតុ** ឧការន្ត ឥ., **ជម្ពូ** ឩការន្ត ឥ., **គោ** ឱការន្ត ឥ. ។

* * * * * * * *

# ៣. នបុំសកលិង្គ

**ចិត្ត** [ ចិត្ត ] អការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ចិត្តំ | ចិត្តា ចិត្តានិ |
| អា. | ចិត្ត | ចិត្តា ចិត្តានិ |
| ទុ. | ចិត្តំ | ចិត្តេ ចិត្តានិ |
| ត. | ចិត្តេន | ចិត្តេហិ ចិត្តេភិ |
| ច. | ចិត្តស្ស | ចិត្តានំ |
| មី. | ចិត្តា ចិត្តស្មា ចិត្តម្ហា | ចិត្តេហិ ចិត្តេភិ |
| ឆ. | ចិត្តស្ស | ចិត្តានំ |
| ស. | ចិត្តេ ចិត្តស្មឹ ចិត្តម្හិ | ចិត្តេសុ |

**កម្ម** [ កម្ម,អំពើ ទង្វើ,ការងារ ] អការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | កម្មំ | កម្មា កម្មានិ |
| អា. | កម្ម | កម្មា កម្មានិ |
| ទុ. | កម្មំ | កម្មេ កម្មានិ |
| ត. | កម្មុនា កម្មនា កម្មេន | កម្មេហិ កម្មេភិ |
| ច. | កម្មុនោ កម្មស្ស | កម្មានំ |
| មី. | កម្មុនា កម្មា កម្មស្មា កម្មម្ហា | កម្មេហិ កម្មេភិ |
| ឆ. | កម្មុនោ កម្មស្ស | កម្មានំ |
| ស. | កម្មនិ កម្មេ កម្មស្មឹ កម្មម្ហិ | កម្មេសុ |

## សព្វបំបែកដូច ចិត្ត

បុញ្ញ បាប ផល រូប សាធនំ, សោត ឃាន សុខ ទុក្ខ ការណំ
ទាន សីល ធន ឈាន លោចនំ, មូល កូល ពល ជាល មង្គលំ.
នទ្បិន លិង្គ មុខង្គ ជលម្ពុជំ បុលិន ធញ្ញ ហិរញ្ញ បទាមតំ
បទុម បណ្ណ សុសាន វនាយុធំ ហាទយ ចីវរ វត្ថ កុលិន្ទ្រិយំ.

នយន វទន យានោទាន សោបាន បានំ
ភវន ភុវន លោហាលាត តុណ្ឌាណ្ឌ បីបំ
ករណ មរណ ញាណារម្មណារញ្ញ តាណំ
ចរណ នគរ តីរច្ឆត្ត ឆិទ្ទោទកានិ. (បទរូបសិទ្ធិ)

* * * * * * * * * *

ចិត្តមស្សទ្ធមាបានំ បុញ្ញំ បាបំ បទំ មុខំ
លោហាលាតំ កុលំ កូលំ នទ្បិនំ បុលិនាយុធំ
តុណ្ឌាណ្ឌំ បត្តនំ បីបំ ភវនំ ភុវនំ វនំ
រូបំ កម្មំ ផលំ សោតំ ឃានំ ករណការណំ
សុខំ ទុក្ខំ ធនំ ទានំ សីលំ ឈានំ ពលំ ជលំ
លោចនំ មកុដំ មូលំ លិង្គង្គំ បទុមម្ពុជំ
បណ្ណំ ធញ្ញាមតំ ជាលំ ហិរញ្ញំ ហាទយិន្ទ្រិយំ
សុសានំ ចីវរំ វត្ថំ នយនំ វទនោទកំ
យានុយ្យានុទ្ធានំ បានំ សោបានំ តីរសាធនំ
ញាណារម្មណាលម្ពនំ តាណារញ្ញំ ឃរំ គហំ
ចរណំ នគរំ ឆត្តំ ឆិទ្ទំ មរណមាននំ ។ (កច្ចាយនសុត្តត្ថៈ)

## សព្ទបំបែកដូច ចិត្ត

* * * * * * * *

**បុញ្ញ** = បុណ្យ, **បាប** = បាប, **ផល** = ផល ផ្លែ, **រូប** = រូប, **សាធន** = សេចក្តីសម្រេច, **សោត** = ត្រចៀក, **យាន** = ច្រមុះ, **សុខ** = សុខ, **ទុក្ខ** = ទុក្ខ, **ការណ** = ហេតុ, **ទាន** = ការឲ្យ, **សីល** = សីល, **ធន** = ទ្រព្យ លុយ, **ឈាន** = ឈាន, **លោចន** = កែវភ្នែក, **មូល** = ឫស, **កូល** = ច្រាំង, **ពល** = កម្លាំង **ជាល** = សំណាញ់ **មង្គល** = មង្គល, **នទ្បិន** = ផ្កាឈូក, **លិង្គ** = គ្រឿងសម្គាល់ ភេទ, **មុខ** = មាត់, **អង្គ** = អវយវៈ **ជល** = ទឹក, **អម្ពុជ** = ផ្កាឈូក, **បុលិន** = ខ្សាច់, **ធញ្ញ** = ស្រូវ, **ហិរញ្ញ** = ប្រាក់, **បទ** = ជើង, **អមត** = និព្វាន, **បទុម** = ផ្កាឈូក, **បណ្ណ** = ស្លឹកឈើ, **សុសាន** = ប៉ាឆា, **វន** = ព្រៃ, **អាយុធ** = អាវុធ, **ហទយ** = បេះដូង, **ចីវរ** = ចីពរ, **វត្ថ** = សំពត់, **កុល** = ត្រកូល, **ឥន្ទ្រិយ** = ឥន្ទ្រីយ៍, **នយន** = ភ្នែក, **វទន** = មាត់, **យាន** = យានពាហនៈ, **ឧទាន** = ពាក្យបន្លឺ, **សោបាន** = ជណ្តើរ, **បាន** = ទឹកភេសជ្ជៈ, **ភវន** = បន្ទប់ លំនៅ **ភុវន** = លោក, **លោហ** = លោហៈ, **អលាត** = ដុំភ្លើង, **តុណ្ឌ** = ចំពុះ, **អណ្ឌ** = ពងស៊ុត, **បីឋ** = កៅអី តាំង ជើងតាំង ជើងម៉ា, **ករណ** = វត្ថុជាគ្រឿងធ្វើ, **មរណ** = សេចក្តីស្លាប់, **ញាណ** = ចំណេះដឹង, **អារម្មណ** = អារម្មណ៍, **អរញ្ញ** = ព្រៃ, **តាណ** = គ្រឿងការពារ ទីពឹង **ចរណ** = ជើង, **នគរ** = ក្រុង ខែត្រ, **តីរ** = ត្រើយ, **ឆត្ត** = ឆត្រ, **ឆិទ្ទ** = ប្រហោង, **ឧទក**= ទឹក, **ចិត្ត** = ចិត្ត, **អស្សទ្ធ** = ត្រកូលឥតសទ្ធា, **អាបាន** = តៀមស្រា, **បត្តន** = កំពង់ផែ, **មកុជ** = ម្កុដ, **ឧយ្យាន** = ឧទ្យាន, **ឧទ្ធាន** = ចំណងជើង, **អាលម្ពន** = អារម្មណ៍ តំណោង, **ឃរ** = ផ្ទះ, **គហ** = ផ្ទះ, **អានន** = មុខ ។

* * * * * * * *

**ថាម** [ កម្លាំង,ថាមពល ] អការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ថាមំ | ថាមា ថាមានិ |
| អា. | ថាម | ថាមា ថាមានិ |
| ទុ. | ថាមំ | ថាមេ ថាមានិ |
| ត. | ថាមសា ថាមេន ថាមុនា | ថាមេហិ ថាមេភិ |
| ច. | ថាមសោ ថាមស្ស ថាមុនោ | ថាមានំ |
| មី. | ថាមា ថាមស្មា ថាមម្ហា ថាមុនា | ថាមេហិ ថាមេភិ |
| ឆ. | ថាមសោ ថាមស្ស ថាមុនោ | ថាមានំ |
| ស. | ថាមសិ ថាមេ ថាមស្មឹ ថាមម្ហិ | ថាមេសុ |

**អទ្ធ** [ ផ្លូវឆ្ងាយ,កាលយូរអង្វែង ] អការន្ត បុំ. នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អទ្ធា/អទ្ធំ | អទ្ធា អទ្ធានោ/អទ្ធានិ |
| អា. | អទ្ធ | អទ្ធា អទ្ធានោ/អទ្ធានិ |
| ទុ. | អទ្ធានំ | អទ្ធានេ អទ្ធានោ/អទ្ធានិ |
| ត. | អទ្ធុនា | អទ្ធានេហិ អទ្ធានេភិ |
| ច. | អទ្ធុនោ | អទ្ធានំ |
| មី. | អទ្ធុនា | អទ្ធានេហិ អទ្ធានេភិ |
| ឆ. | អទ្ធុនោ | អទ្ធានំ |
| ស. | អទ្ធនិ អទ្ធានេ | អទ្ធានេសុ |

**គុណវន្តុ** [ ដែលមានគុណ ] ឧការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គុណវំ | គុណវន្តិ គុណវន្តានិ |
| អា. | គុណវំ គុណវ គុណវា | គុណវន្តិ គុណវន្តានិ |
| ទុ. | គុណវន្តំ | គុណវន្តេ គុណវន្តានិ |
| ត. | គុណវតា គុណវន្តេន | គុណវន្តេហិ គុណវន្តេភិ |
| ច. | គុណវតោ គុណវន្តស្ស | គុណវតំ គុណវន្តានំ |
| មី. | គុណវតា គុណវន្តា គុណវន្តស្មា គុណវន្តម្ហា | គុណវន្តេហិ គុណវន្តេភិ |
| ឆ. | គុណវតោ គុណវន្តស្ស | គុណវតំ គុណវន្តានំ |
| ស. | គុណវតិ គុណវន្តេ គុណវន្តស្មឹ គុណវន្តម្ហិ | គុណវន្តេសុ |

**គច្ឆន្ត** [ កំពុងទៅ ] អការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គច្ឆំ គច្ឆន្តំ | គច្ឆន្តា គច្ឆន្តានិ |
| អា. | គច្ឆំ គច្ឆ គច្ឆា | គច្ឆន្តា គច្ឆន្តានិ |
| ទុ. | គច្ឆន្តំ | គច្ឆន្តេ គច្ឆន្តានិ |
| ត. | គច្ឆតា គច្ឆន្តេន | គច្ឆន្តេហិ គច្ឆន្តេភិ |
| ច. | គច្ឆតោ គច្ឆន្តស្ស | គច្ឆតំ គច្ឆន្តានំ |
| មី. | គច្ឆតា គច្ឆន្តា គច្ឆន្តស្មា គច្ឆន្តម្ហា | គច្ឆន្តេហិ គច្ឆន្តេភិ |
| ឆ. | គច្ឆតោ គច្ឆន្តស្ស | គច្ឆតំ គច្ឆន្តានំ |
| ស. | គច្ឆតិ គច្ឆន្តេ គច្ឆន្តស្មឹ គច្ឆន្តម្ហិ | គច្ឆន្តេសុ |

**អស្សទ្ធា** [ គ្មានសទ្ធា ] អាការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អស្សទ្ធំ | អស្សទ្ធា អស្សទ្ធានិ |
| អា. | អស្សទ្ធ | អស្សទ្ធា អស្សទ្ធានិ |
| ទុ. | អស្សទ្ធំ | អស្សទ្ធេ អស្សទ្ធានិ |
| ត. | អស្សទ្ធេន | អស្សទ្ធេហិ អស្សទ្ធេភិ |
| ច. | អស្សទ្ធស្ស | អស្សទ្ធានំ |
| មី. | អស្សទ្ធា អស្សទ្ធស្មា អស្សទ្ធម្ហា | អស្សទ្ធេហិ អស្សទ្ធេភិ |
| ឆ. | អស្សទ្ធស្ស | អស្សទ្ធានំ |
| ស. | អស្សទ្ធេ អស្សទ្ធស្មឹ អស្សទ្ធម្ហិ | អស្សទ្ធេសុ |

**មុខនាសិកា** [ មាត់និងច្រមុះ ] អាការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. |
|---|---|
| ប. | មុខនាសិកំ |
| អា. | មុខនាសិក |
| ទុ. | មុខនាសិកំ |
| ត. | មុខនាសិកេន |
| ច. | មុខនាសិកស្ស |
| មី. | មុខនាសិកា មុខនាសិកស្មា មុខនាសិកម្ហា |
| ឆ. | មុខនាសិកស្ស |
| ស. | មុខនាសិកេ មុខនាសិកស្មឹ មុខនាសិកម្ហិ |

**អដ្ឋិ** [ ឆ្អឹង,គ្រាប់ផ្លែឈើ ] ឥការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អដ្ឋិ | អដ្ឋី អដ្ឋីនិ |
| អា. | អដ្ឋិ | អដ្ឋី អដ្ឋីនិ |
| ទុ. | អដ្ឋឹ | អដ្ឋី អដ្ឋីនិ |
| ត. | អដ្ឋិនា | អដ្ឋីហិ-អដ្ឋីភិ អដ្ឋិហិ-អដ្ឋិភិ |
| ច. | អដ្ឋិនោ អដ្ឋិស្ស | អដ្ឋីនំ អដ្ឋិនំ |
| មី. | អដ្ឋិនា អដ្ឋិស្មា អដ្ឋិម្ហា | អដ្ឋីហិ-អដ្ឋីភិ អដ្ឋិហិ-អដ្ឋិភិ |
| ឆ. | អដ្ឋិនោ អដ្ឋិស្ស | អដ្ឋីនំ អដ្ឋិនំ |
| ស. | អដ្ឋិស្មឹ  អដ្ឋិម្ហិ | អដ្ឋីសុ អដ្ឋិសុ |

**សុខការី** [ ដែលធ្វើនូវសេចក្ដីសុខ ] ឦការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សុខការិ | សុខការី សុខការីនិ |
| អា. | សុខការិ | សុខការី សុខការីនិ |
| ទុ. | សុខការិនំ សុខការឹ | សុខការី សុខការីនិ |
| ត. | សុខការិនា | សុខការីហិ សុខការីភិ |
| ច. | សុខការិនោ សុខការិស្ស | សុខការីនំ |
| មី. | សុខការិនា សុខការិស្មា សុខការិម្ហា | សុខការីហិ សុខការីភិ |
| ឆ. | សុខការិនោ សុខការិស្ស | សុខការីនំ |
| ស. | សុខការិនិ សុខការិស្មឹ សុខការិម្ហិ | សុខការីសុ |

## សព្ទបំបែកដូច អដ្ឋិ

* * * * * * * *

អដ្ឋិ សត្ថិ ទធក្ខច្ឆិ វារិ សប្បិ នបុំសកា.

* * * * * * * * * *

**សត្ថិ** = ភ្លៅ, **ទធិ** = ទឹកដោះជូរ, **វារិ** = ទឹក, **អក្ខិ** = ភ្នែក, **អច្ឆិ** = ភ្នែក, **អច្ចិ** = អណ្តាតភ្លើង, **សប្បិ** = ទឹកដោះថ្លា ។

## សព្ទបំបែកដូច សុខការី

**សីឃយាយី** = អ្នកទៅលឿន, **ព្រហ្មចារី** = ព្រហ្មចារី, **សច្ចវាទី** = អ្នកនិយាយការពិត, **បាបការី** = អ្នកធ្វើបាប, **ធម្មចារី** = អ្នកប្រព្រឹត្តធម៌ ។

* * * * * * *

**អាយុ** [ អាយុ ] ឧការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | អាយុ | អាយូ អាយូនិ |
| អា. | អាយុ | អាយូ អាយូនិ |
| ទុ. | អាយុំ | អាយូ អាយូនិ |
| ត. | អាយុនា អាយុសា | អាយូហិ-អាយូភិ អាយុហិ-អាយុភិ |
| ច. | អាយុនោ អាយុស្ស | អាយូនំ អាយុនំ |
| មី. | អាយុនា អាយុស្មា អាយុម្ហា | អាយូហិ-អាយូភិ អាយុហិ-អាយុភិ |
| ឆ. | អាយុនោ អាយុស្ស | អាយូនំ អាយុនំ |
| ស. | អាយុស្មឹ អាយុម្ហិ | អាយូសុ អាយុសុ |

**គោត្រភូ** [ គោត្រភូ ] ឩការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | គោត្រភុ | គោត្រភូ គោត្រភូនិ |
| អា. | គោត្រភុ | គោត្រភូ គោត្រភូនិ |
| ទុ. | គោត្រភុំ | គោត្រភូ គោត្រភូនិ |
| ត. | គោត្រភុនា | គោត្រភូហិ  គោត្រភូភិ |
| ច. | គោត្រភុនោ គោត្រភុស្ស | គោត្រភូនំ |
| មី. | គោត្រភុនា គោត្រភុស្មា គោត្រភុម្ហា | គោត្រភូហិ គោត្រភូភិ |
| ឆ. | គោត្រភុនោ គោត្រភុស្ស | គោត្រភូនំ |
| ស. | គោត្រភុស្មឹ  គោត្រភុម្ហិ | គោត្រភូសុ |

អភិភូ, សយម្ភូ, ធម្មញ្ញូ បំបែកដូច គោត្រភូ

## សព្ទបំបែក ដូច អាយុ

អាយុ ចក្ខុ វសុ ទារុ    មធ្វម្ពុ តិបុ ហិង្គុ ច

សិគ្គុ មត្ថុ វត្ថុ ជតុ    សាល្វស្សុ ផលុ ពិន្ទុ ច.

**ចក្ខុ** = ភ្នែក, **វសុ** = ទ្រព្យ, **ធនុ** = ធ្នូ ស្នា, **ទារុ** = ឧស, **តិបុ** = សំណប៉ាហាំង, **មធុ** = ទឹកឃ្មុំ, **អម្ពុ** = ទឹក, **ហិង្គុ** = មហាហឹង្គុ, **សិង្គុ** = ម្រុំ , **វត្ថុ** = រឿង វត្ថុ, **មត្ថុ** = ប្រេង ទឹកដោះរាវថ្លា, **ជតុ** = ល័ខ, **អស្សុ** = ទឹកភ្នែក, **សាលុ** = ក្រអៅឈូក, **ផលុ** = ថ្នាំង, **ពិន្ទុ** = ចំណុច ពិន្ទុ និគ្គហិត ដំណក់ទឹក

* * * * * * *

**ចិត្តគោ** [ ដែលមានគោពពាល ]  ឱការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | ចិត្តគុ | ចិត្តគូ ចិត្តគូនិ |
| អា. | ចិត្តគុ | ចិត្តគូ ចិត្តគូនិ |
| ទុ. | ចិត្តគុំ | ចិត្តគូ ចិត្តគូនិ |
| ត. | ចិត្តគុនា | ចិត្តគូហិ-ចិត្តគូភិ ចិត្តគុហិ-ចិត្តគុភិ |
| ច. | ចិត្តគុនោ ចិត្តគុស្ស | ចិត្តគូនំ ចិត្តគុនំ |
| មី. | ចិត្តគុនា ចិត្តគុស្មា ចិត្តគុម្ហា | ចិត្តគូហិ-ចិត្តគូភិ ចិត្តគុហិ-ចិត្តគុភិ |
| ឆ. | ចិត្តគុនោ ចិត្តគុស្ស | ចិត្តគូនំ ចិត្តគុនំ |
| ស. | ចិត្តគុស្មឹ  ចិត្តគុម្ហិ | ចិត្តគូសុ ចិត្តគុសុ |

---

## នាម ៣ យ៉ាង

១. នាមបុល្លិង្គ មាន ៧ ការន្ត គឺ បុរិសាទិគណៈ, សាទិគណៈ, អគ្គិយាទិគណៈ, ទណ្ឌិយាទិគណៈ, ភិក្ខុវាទិគណៈ, អភិភាទិគណៈ និង គោ សព្ទ ។

២. នាមឥត្ថិលិង្គ  មាន ៦ ការន្ត គឺ កញ្ញាទិគណៈ, រត្តិយាទិគណៈ, ឥត្ថិយាទិគណៈ, យាគុអាទិគណៈ, ជម្ពូអាទិគណៈ និង គោ សព្ទ ។

៣. នាមនបុំសកលិង្គ មាន ៧ ការន្ត គឺ ចិត្តាទិគណៈ, អស្សទ្ធាទិគណៈ, អដ្ឋាទិគណៈ, សុខការិយាទិគណៈ, អាយាទិគណៈ, គោត្រភាទិគណៈ និង ចិត្តគោ សព្ទ ។

---

## សង្គហគាថា

ចិត្តំ កម្មញ្ច អស្សទ្ធ- មថង្គិ សុខការិ ច
អាយុ គោត្រភុ ធម្មញ្ញូ ចិត្តគូតិ នបុំសកេ.

## សរុបការន្តនបុំសកលិង្គ

**ចិត្ត** អការន្ត នបុំ, **កម្ម** អការន្ត នបុំ, **ថាម** អការន្ត នបុំ, អទ្ធ អការន្ត នបុំ, **គុណវន្តុ** ឧការន្ត នបុំ, **គច្ឆន្ត** អការន្ត នបុំ, **អស្សទ្ធា** អាការន្ត នបុំ, **មុខនាសិកា** អាការន្ត នបុំ, **អដ្ឋិ** ឥការន្ត នបុំ, **សុខការី** ឦការន្ត នបុំ, **អាយុ** ឧការន្ត នបុំ, **គោត្រភូ** ឩការន្ត នបុំ, **ចិត្តគោ** ឱការន្ត នបុំ. ។

# ៤. សព្ពនាម

នាមដែលប្រើជំនួសនាមសព្ទបានទាំង ៣ លិង្គ ឈ្មោះថា **សព្ពនាម** ។ មាន ២៧ សព្ទ ចែកជា ៧ ក្រុម គឺ

១. **សព្ព** ( ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, រាល់, គ្រប់ ), **ឧភយ** ( ទាំងពីរ )

២. **កតរ** ( ណា, មួយណា, ណាខ្លះ, ប៉ុន្មាន ), **កតម** ( ណា, មួយណា, ណាខ្លះ, ប៉ុន្មាន ), **ឥតរ** ( ក្រៅនេះ ), **អញ្ញ** ( ដទៃ ), **អញ្ញតរ** ( មួយរូប, មួយនាក់, មួយអង្គ,ន៉ាមួយ ), **អញ្ញតម** ( មួយរូប, មួយនាក់, មួយអង្គ, ន៉ាមួយ )

៣. **បុព្ព** ( ទិសខាងកើត, ខាងមុខ ), **បរ** ( ទិសខាងលិច, ខាងក្រោយ ), **អបរ** ( ទិសខាងលិច, ខាងក្រោយ ), **ទក្ខិណ** ( ទិសខាងត្បូង, ខាងស្តាំ ), **ឧត្តរ** ( ទិសខាងជើង, ខាងលើ ), **អធរ** ( ទិសខាងក្រោម, ខាងក្រោម )

៤. **យ** ( ន៉ា,ឯន៉ា ), **ត** ( នោះ ), **ឯត** ( ហ្នឹង, និះ, នុះ ), **ឥម** ( នេះ )

៥. **អមុ** ( ឯណោះ ), **កឹ** ( អ្វី អ្នកណា ), **ឯក** ( មួយ ), [**ឯកច្ច** ( ពួកខ្លះ )]

៦. **ឧភ** ( ទាំងពីរ ), **ទ្វិ** ( ពីរ ), **តិ** ( បី ), **ចតុ**( បួន )

៧. **តុម្ហ** ( លោក, អ្នក, ឯង ), **អម្ហ** ( យើង, ខ្ញុំ )  [ តាមគម្ពីរបទរូបសិទ្ធិ ] ។

សទ្ទនីតិបករណ៍ បទមាលា ប្រាប់ថា **បុព្ព** សព្ទជាដើម អាចជាសុទ្ធនាម( នាមនាម )បានទៀត គឺ **បុព្ព** ( ខ្ទុះ, ប្រធាន ), **បរ** ( សត្រូវ, ប្រសើរ ), **ទក្ខិណ** ( ទក្ខិណា ), **ឧត្តរ** ( ប្រសើរ, ចម្លើយ, សំពត់ដណ្តប់ ), **អញ្ញ** ( អរហត្តផល ) ។

តាមធម្មតា សព្ពនាមច្រើនតែប្រទះឃើញនៅក្នុងប្រយោគទី ២ ជាដើមទៅ ដើម្បីពោលដល់បុគ្គល ឬ វត្ថុ ដែលបានពោលរួចមកហើយក្នុងប្រយោគមុន ដូចជា

**បុរិសោ** គាមំ គច្ឆតិ. បុរស ទៅ ភូមិ ។ **សោ** ភិក្ខុំ បស្សិត្វា វន្ទតិ. គាត់ ( បុរសនោះ ) ឃើញលោកហើយក៏សំពះ ។ ពាក្យថា **សោ** ( គាត់, បុរសនោះ ) មកពី ត សព្ពនាម + សិ វិភត្តិ ប្រើជំនួស **បុរិសោ** ដែលបានពោលរួចមកហើយក្នុងប្រយោគមុន ។

-**កញ្ញា** គាមំ គច្ឆតិ.  ស្រីក្រមុំ ទៅ ភូមិ ។

- **សា** ភិក្ខុំ បស្សិត្វា វន្ទតិ. នាង ( កញ្ញានោះ ) ឃើញលោកហើយក៏សំពះ ។

ពាក្យថា **សា** ( នាង,កញ្ញានោះ ) មកពី ត សព្វនាម + សិ វិភត្តិ ប្រើជំនួស **កញ្ញា** ដែលបានពោលរួចមកហើយក្នុងប្រយោគមុន ។

-ភិក្ខុនោ **ចីវរំ** ហោតិ. ចីវរ របស់ភិក្ខុ មាន ។

-**តំ** អន្តរធាយតិ. វា បាត់ទៅ ។

ពាក្យថា **តំ** (វា,ចីវរនោះ ) មកពី ត សព្វនាម + សិ វិភត្តិ ប្រើជំនួស **ចីវរំ** ដែលបានពោលរួចមកហើយក្នុងប្រយោគមុន ។

---

**សព្វ** [ ទាំងពួង ] អការន្ត បុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សព្វោ | សព្វេ |
| អា. | សព្វ | សព្វេ |
| ទុ. | សព្វំ | សព្វេ |
| ត. | សព្វេន | សព្វេហិ សព្វេភិ |
| ច. | សព្វស្ស | សព្វេសំ សព្វេសានំ |
| បំ. | សព្វស្មា សព្វម្ហា | សព្វេហិ សព្វេភិ |
| ឆ. | សព្វស្ស | សព្វេសំ សព្វេសានំ |
| ស. | សព្វស្មឹ សព្វម្ហិ | សព្វេសុ |

**សព្វា** [ ទាំងពួង ] អាការន្ត ឥ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សព្វា | សព្វា សព្វាយោ |
| អា. | សព្វេ | សព្វា សព្វាយោ |
| ទុ. | សព្វំ | សព្វា សព្វាយោ |
| ត. | សព្វាយ | សព្វាហិ សព្វាភិ |
| ច. | សព្វស្សា សព្វាយ | សព្វាសំ សព្វាសានំ |
| មី. | សព្វាយ | សព្វាហិ សព្វាភិ |
| ឆ. | សព្វស្សា សព្វាយ | សព្វាសំ សព្វាសានំ |
| ស. | សព្វស្សំ សព្វាយំ | សព្វាសុ |

**សព្វ** [ ទាំងពួង ] អការន្ត នបុំ. បំបែក ដូច្នេះ

| | ឯក. | ពហុ. |
|---|---|---|
| ប. | សព្វំ | សព្វានិ |
| អា. | សព្វ | សព្វានិ |
| ទុ. | សព្វំ | សព្វានិ |
| ត. | សព្វេន | សព្វេហិ សព្វេភិ |
| ច. | សព្វស្ស | សព្វេសំ សព្វេសានំ |
| មី. | សព្វស្មា សព្វម្ហា | សព្វេហិ សព្វេភិ |
| ឆ. | សព្វស្ស | សព្វេសំ សព្វេសានំ |
| ស. | សព្វស្មឹ សព្វម្ហិ | សព្វេសុ |

**កតរ, កតម, ឧភយ, ឥតរ, អញ្ញ, អញ្ញតរ, អញ្ញតម** បំបែកដូច **សព្វ** ទាំង ៣ លិង្គ ។

**កតរកតម** [ ពួកណាខ្លះ ] អការន្ត បុំ. បំបែក ដូច្នេះ

ពហុ.

ប. កតរកតមេ កតរកតមា

អា. កតរកតមេ កតរកតមា

ទុ. កតរកតមេ

ត. កតរកតមេហិ កតរកតមេភិ

ច. កតរកតមានំ

មី. កតរកតមេហិ កតរកតមេភិ

ឆ. កតរកតមានំ

ស. កតរកតមេសុ

